ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 10-Aug-2020, 09:26
CMS/CFO: Sann Rada

សំណុំរឿងលេខ: ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក
Case File/Dossier N°. 004/2/07-09-2009-ECCC/TC/SC

នៅចំពោះមុខ៖
ចៅក្រម គង់ ស្រ៊ឹម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele Mwachande MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen Harding CLARK
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២០
ភាសាដើម៖ ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខផ្ទាល់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង

**សហព្រះរាជអាជ្ញា**

ជា លាង
Brenda J. HOLLIS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

**ជនជាប់ចោទ**

អោ អាន

**សហមេធាវីជនជាប់ចោទ**

មុំ លុជ្ស
Richard ROGERS
Goran SLUITER

ហុង គឹមសួន

ឡោ ជុនធី

សំ សុគង់

ស៊ិន សាវន

Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Nushin SARKARATI

ជេត វណ្ណលី

គឹម ម៉េងឃី

ទី ស្រ៊ីនណា

វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Lyma NGUYEN

1. **អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ (“អង្គជំនុំជម្រះតុលាការកំពូល” ឬ“អង្គជំនុំជម្រះ” និង “អ.វ.ត.ក” នីមួយៗ) បានទទួល“បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង”)[1]។

## ក. <u>សេចក្តីផ្តើម</u>

2. សហព្រះរាជអាជ្ញាអន្តរជាតិដែលបានធ្វើបណ្តឹងសាទុក្ខភ្លាមៗតែឯកឯងប្រឆាំងនឹង អ្វីដែលខ្លួនបានកំណត់ចរិតលក្ខណៈថា ជាការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចាប់ផ្តើមការជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ បន្ទាប់ពីមានការដាក់*សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ* នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៩[2] ដែលក្នុងនោះ ពុំទទួលបានមតិភាគច្រើនវិជ្ជមានដែលតម្រូវយ៉ាងតិចពីចៅក្រមបួនរូប (“មតិភាគច្រើនលើសលុប”) ពាក់ព័ន្ធទៅនឹងដីកាដំណោះស្រាយពីរផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា។ អង្គបុរេជំនុំជម្រះបានសម្រេចដោយឯកច្ឆន្ទលើបញ្ហាមួយចំនួនរួមទាំង“*ថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ ដោយរំលោភលើក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក.*” ប៉ុន្តែ ទោះជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះបានយល់ឃើញដោយមានការខ្វែងយោបល់គ្នាថា ដីកាដំណោះស្រាយដែលចេញដោយសហចៅក្រមស៊ើបអង្កេតជាតិ ដែលបានសម្រេចលើកលែងចោទប្រកាន់ អោ អាន មានសុពលភាព(ចៅក្រមអន្តរជាតិជំទាស់) ហើយដីកាចោទប្រកាន់ដែលចេញដោយ

[1] បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពនៃសំណុំរឿង ០០៤/២ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០ ឯកសារលេខ E004/2/1 (“បណ្តឹងសាទុក្ខភ្លាមៗ”)។

[2] អង្គបុរេជំនុំជម្រះ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D359/24 និង D360/33 ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៩ (“*សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ*”)។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលសម្រេចបញ្ជូនរឿងក្ដីទៅជំនុំជម្រះ មានសុពលភាព(ចៅក្រមជាតិជំទាស់)[3]។

3. ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា រឿងក្ដីនេះបន្ទាប់មកបានមកដល់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយមិនអាចរកសំឡេងភាគច្រើនដែលតម្រូវបាន(“*គោលជំហរមិនពេញលេញ*”) អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង និងថា ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការធ្វើចំណាត់ការលើដីកាដំណោះស្រាយ បានធ្វើឱ្យអានុភាពនៃសំណុំរឿង ០០៤/២ ប្រឆាំងនឹង អោ អាន ត្រូវបញ្ចប់ ជាផលវិបាកនាំឱ្យមានការដាក់បណ្ដឹងសាទុក្ខភ្លាមៗនេះ[4]។

## ២. ប្រវត្តិនីតិវិធី

4. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សេចក្ដីជំទាស់មួយនៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយបានអះអាងថា សហព្រះរាជអាជ្ញាជាតិបានជំទាស់ទៅនឹងការចោទប្រកាន់លើបទឧក្រិដ្ឋថ្មី និងជនសង្ស័យថ្មី ដែលបានកំណត់អត្តសញ្ញាណនៅក្នុងសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីដែលបានស្នើឡើងនោះ[5]។ នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីពិចារណារបស់ខ្លួនដោយបញ្ជាក់ថា អង្គបុរេនៅពុំទាន់ទទួលបានការសម្រេចណាមួយឡើយលើការខ្វែងយោបល់ដែលបានដាក់ចំពោះមុខខ្លួន អាស្រ័យហេតុនេះ សកម្មភាពរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវតែយកទៅអនុវត្ត[6]។

---

[3] ដីកាដំណោះស្រាយលើកលែងចោទប្រកាន់ ឯកសារលេខ D359 ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៨ “ដីកាលើកលែងចោទប្រកាន់”)។ ដីកាដំណោះស្រាយ(បញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារលេខ D360 ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៨ (“ដីកាបញ្ជូនរឿងទៅជំនុំជម្រះ”) ជារួមសំដៅលើ“ដីកាដំណោះស្រាយ”។

[4] បណ្ដឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ១។

[5] ការលើកឡើងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីអំពីអង្គហេតុ និងសំអាងហេតុសម្រាប់ការខ្វែងយោបល់គ្នាអនុលោមតាម វិធាន ៧១(២) នៃវិធានផ្ទៃក្នុង ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារលេខ 1។

[6] សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ស្របតាមវិធាន ៧១ ឯកសារលេខ D1/1.3 ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ កថាខណ្ឌ ៤៥។

5. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីដែលរងការជំទាស់ ដោយបានស្នើសុំសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការប្រឆាំងនឹង អោ អាន *ដែលក្នុងចំណោមនោះ* ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រល័យពូជសាសន៍ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៥៦[7]។ សេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនប្រាំមួយដែលមានការចោទប្រកាន់បន្ថែមនោះ បានដាក់នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១[8] ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១[9] ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤[10] ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥[11] ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៥[12] និងថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦[13]។

---

[7] សេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបីរបស់សហព្រះរាជអាជ្ញា ឯកសារលេខ D1 ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ (“សេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី”)។

[8] សំណុំរឿងលេខ 004/07-09-2009-ECCC/OCIJ (“សំណុំរឿង ០០៤”) សេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធទៅនឹងផ្នែកទីមួយ ទីកន្លែងបទឧក្រិដ្ឋ និងការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោម ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ D27 *សូមមើលផងដែរ* សំណុំរឿង ០០៤ សេចក្ដីសម្រេចលើសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងផ្នែកទីមួយ ទីកន្លែងឧក្រិដ្ឋកម្ម និងការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោម ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ D27/3។

[9] សំណុំរឿង ០០៤ សេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងផ្នែកទីមួយ ទីកន្លែងឧក្រិដ្ឋកម្ម និងការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោម ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ D65។

[10] សំណុំរឿង ០០៤ សេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈ ឬផ្អែកលើភេទ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារលេខ D191។

[11] សំណុំរឿង ០០៤ សារណាតបទៅនឹងដីបញ្ជូនរឿង ឯកសារលេខ D237 ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារលេខ D237/1។

[12] សំណុំរឿង ០០៤ សារណាតបទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យ និងសេចក្ដីសន្និដ្ឋានបញ្ជូនរឿងបន្ថែមពាក់ព័ន្ធទៅនឹងវត្តតាមាក់ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៥ ឯកសារលេខ D254/1។

[13] សំណុំរឿង ០០៤ សារណាតបទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើការរៀបការដោយបង្ខំក្នុងផ្នែកទី ១ និង ៤ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ D272/1។

6. ការខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេតក្នុងរឿងក្តីនេះ ត្រូវបានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៥ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ និង ១៦ ខែ មករា ឆ្នាំ ២០១៧ និង ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៨[14]។

7. នៅថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ អោ អាន ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានលើមាត្រា ៥០១ និង ៥០៦ (មនុស្សឃាតគិតទុកជាមុន)នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៥៦[15]។ នៅថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ អោ អាន បន្ថែមពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងប្រល័យពូជសាសន៍[16]។

8. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿង ០០៤/២ (“សំណុំរឿង”) ទៅសហព្រះរាជអាជ្ញាដោយបានអញ្ជើញសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានស្ថាពរ ដោយអនុលោមតាមវិធាន ៦៦(៤)[17]។ នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាជាតិ បានដាក់សេចក្តីសន្និដ្ឋានស្ថាពរស្នើសុំថា រាល់បទចោទប្រឆាំងនឹង អោ អាន ត្រូវបដិសេធចោលដោយផ្អែកលើមូលដ្ឋានថា ជនសង្ស័យពុំមែនជាមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និងពុំស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្មក្រោមយុត្តាធិការរបស់ អ.វ.ត.ក. ឡើយ[18] ចំណែកឯសហព្រះរាជអាជ្ញាអន្តរជាតិ កាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧ បានដាក់សេចក្តីសន្និដ្ឋានស្ថាពរស្នើសុំថា អោ អាន ត្រូវទទួលរងការចោទប្រកាន់ និងត្រូវបញ្ជូនទៅជំនុំជម្រះ[19]។

---

[14] ការខ្វែងយោបល់គ្នាសម្ងាត់។

[15] សំណុំរឿង ០០៤ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃបង្ហាញខ្លួនដំបូងរបស់ អោ អាន ឯកសារលេខ D242 ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥។

[16] សំណុំរឿង ០០៤ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការបង្ហាញខ្លួនបន្ថែមទៀតរបស់ អោ អាន ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ឯកសារលេខ D303។

[17] ដីកាបញ្ជូនរឿងអនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារលេខ D351។

[18] សេចក្តីសន្និដ្ឋានចុងក្រោយពាក់ព័ន្ធទៅនឹង អោ អាន អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុងថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ ឯកសារលេខ D351/4។

[19] សេចក្តីសន្និដ្ឋានចុងក្រោយតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧ ឯកសារលេខ D351/5។

9. នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងភាគីថា ផ្អែកលើការខ្វែងយោបល់គ្នានេះ សហចៅក្រមស៊ើបអង្កេតពិចារណាលើដីកាដំណោះស្រាយដែលផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នាដោយអនុលោមតាមច្បាប់ជាធរមាន[20]។ នៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៨ សហចៅក្រមស៊ើបអង្កេត បានចុះបញ្ជីជាផ្លូវការនូវការខ្វែងយោបល់គ្នាពាក់ព័ន្ធទៅនឹងការចេញដីកាដំណោះស្រាយផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា។

10. នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៨ សហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាលើកលែងចោទប្រកាន់លើរឿងក្ដីប្រឆាំងនឹង អោ អាន[21] ខណៈពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាចោទប្រកាន់បញ្ជូនរឿងក្ដី អោ អាន ទៅជំនុំជម្រះ[22]។

11. បន្ទាប់ពីមានបណ្ដឹងឧទ្ធរណ៍បន្តបន្ទាប់ទៅកាន់អង្គបុរេជំនុំជម្រះដែលបានដាក់ដោយសហមេធាវីការពារក្ដី អោ អាន ព្រមទាំងដោយសហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់ និងសហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាចោទប្រកាន់[23] អង្គបុរេជំនុំជម្រះបានចេញ *សេចក្ដីពិចារណា* របស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៩ ដោយពុំបានទទួលមតិភាគច្រើនលើសលុបស្ដីពីសុពលភាពនៃដីកាដំណោះស្រាយទាំងពីរនោះ[24]។ នៅថ្ងៃដដែលនោះ *សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ* ត្រូវបានជូនដំណឹងជាសាធារណៈ ហើយមន្ត្រីកាន់សំណុំរឿង បានធ្វើការជូនដំណឹងតាមរយៈអ៊ីម៉ែលទៅចៅក្រមអង្គជំនុំជម្រះសាលាដំបូង និងក្រឡាបញ្ជី ព្រមទាំងសហចៅក្រមស៊ើបអង្កេតជាតិផងដែរ

---

[20] សេចក្ដីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំបង្ហាញឯកសារពាក់ព័ន្ធទៅនឹងការខ្វែងយោបល់ កថាខណ្ឌ ១៣ ដល់ ១៦ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារលេខ D355/1។

[21] ដីកាលើកលែងចោទប្រកាន់។

[22] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[23] *សូមមើល សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ*កថាខណ្ឌ ១៧ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ៖ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៨ ឯកសារលេខ D360/8/1 និងប្រឆាំងនឹងដីកាចោទប្រកាន់ និងលើកលែងចោទប្រកាន់៖ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៨ ឯកសារលេខ D359/3/1។ បណ្ដឹងឧទ្ធរណ៍របស់ អោ អាន ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៨ ឯកសារលេខ D360/5/1។

[24] *សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ*។

ដោយសារសហចៅក្រមស៊ើបអង្កេតជាតិ គឺជាការិយាល័យតែមួយដែលមានអត្ថិភាពនៃការិយាល័យរបស់សហចៅក្រមស៊ើបអង្កេត[25]។

12. នៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិបានបន្តនីតិវិធីរៀបចំសម្រាប់ការជំនុំជម្រះដោយបានដាក់សំណើនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងសុំពន្យារពេលដាក់បញ្ជីសាក្សី និងអ្នកជំនាញ និងកិច្ចប្រជុំរៀបចំសវនាការ[26]។

13. នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ អោ អាន បានស្នើសុំអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា តើអង្គជំនុំជម្រះបានទទួលសំណុំរឿង ០០៤/២ ឬផ្តល់ការបំភ្លឺដើម្បីឱ្យគាត់អាចដាក់អញ្ញត្រកម្មបឋម និងជាលទ្ធផល ផ្តល់ពេលវេលាគ្រប់គ្រាន់ដល់គាត់ក្នុងការដាក់អញ្ញត្រកម្មនេះ[27]។

14. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ បើទោះបីជាគាត់ពុំទាន់បានទទួលសេចក្តីសម្រេចពីអង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់គាត់សុំពន្យារពេលក៏ដោយ[28]។

15. នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានផ្ញើ អនុស្សរណៈអន្តរការិយាផ្ទាល់ដៃមួយទៅការិយាល័យរដ្ឋបាលស្តីពីដំណើរការសំណុំរឿង ០០៤/២ ដោយបានបង្ហាញពីក្តីបារម្ភថាពុំមានការដាក់ឯកសារណាមួយដែលបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង ត្រូវបានជូនដំណឹងដល់ភាគី និងបានស្នើសុំការិយាល័យរដ្ឋបាលឱ្យចាត់វិធានការចាំបាច់បន្តរឿងក្តី និង/ឬដោះស្រាយការពន្យារពេលនេះ[29]។ នៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០២០ ការិយាល័យរដ្ឋបាលបានឆ្លើយតបថា ខ្លួនអាចត្រឹមតែអនុវត្ត

---

[25] ការជូនដំណឹងតាមអ៊ីមែលពីមន្ត្រីទទួលបន្ទុកសំណុំរឿង ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៩។

[26] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបន្ថែមពេលវេលា ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៩។

[27] អ៊ីមែលផ្ញើជូនចៅក្រមអង្គជំនុំជម្រះសាលាដំបូងពី Goran Sluiter ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩។ លិខិតពីសហមេធាវីការពារក្តីជូនចៅក្រមអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៩ និង ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២០ បានផ្ញើអ៊ីមែលជម្រាបថាបានទទួលឯកសារផ្ញើពីភាគីទៅអង្គជំនុំជម្រះសាលាដំបូង។

[28] សារណាស្តីពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញតាមវិធាន ៨០(១) របស់សហព្រះរាជអាជ្ញា ដោយភ្ជាប់នូវឧបសម្ព័ន្ធសម្ងាត់ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២០។

[29] អនុស្សរណៈអន្តរការិយាល័យ"ដំណើរការនៃសំណុំរឿង ០០៤/២ របស់ អោ អាន" ពីសហព្រះរាជអាជ្ញាអន្តរជាតិទៅអ្នកសម្របសម្រួល UNAKRT ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២០។

តាមសេចក្ដីបង្គាប់របស់អង្គជំនុំជម្រះ ដូចបានលើកឡើងដោយក្រឡាបញ្ជីអង្គជំនុំជម្រះ ដូច្នេះ ការិយាល័យរដ្ឋបាល"បានបំពេញតួនាទីរបស់ខ្លួនត្រឹមត្រូវទាក់ទងទៅនឹងបរិបទនេះ"[30]។

16. នៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០២០ អោ អាន បានដាក់សេចក្ដីសង្ខេបនៃអញ្ញត្រកម្មបឋមរបស់ខ្លួនទៅអង្គជំនុំជម្រះសាលាដំបូងតាមរយៈអ៊ីមែល[31]។

17. នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២០ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា បានទទួលឯកសារដែលបានផ្ញើពីភាគី[32] និងបានកត់សម្គាល់ថា ពុំមាន*សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ* និងសំណុំរឿង និងដីកាចោទប្រកាន់ ត្រូវបានជូនដំណឹង ឬបញ្ជូនមកអង្គជំនុំជម្រះសាលាដំបូងឡើយ[33]។

18. នៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២០ អោ អាន បានដាក់ការឆ្លើយតបជាឯកសារចម្លង និងបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញទៅអង្គជំនុំជម្រះសាលាដំបូង[34]។ នៅថ្ងៃដដែល ផ្នែកបណ្ណសារ និងកត់ត្រាបានទទួលការបង្គាប់ពីរប្រឆាំងគ្នារបស់ក្រឡាបញ្ជីអង្គបុរេជំនុំជម្រះ៖ មួយបង្គាប់ឱ្យជូនដំណឹងសេចក្ដី

---

[30] អនុស្សរណៈអន្តរការិយាល័យ"សំណុំរឿង ០០៤/២"ពីអនុប្រធានការិយាល័យរដ្ឋបាលទៅសហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០២០។

[31] អ៊ីមែលផ្ញើជូនចៅក្រមអង្គជំនុំជម្រះសាលាដំបូង ពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់ អោ អាន ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០២០ និងសេចក្ដីសង្ខេបនៃអញ្ញត្រកម្មបឋមរបស់ អោ អាន តាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង។

[32] *សូមមើល* ឯកសារលេខ D359/36.2 និង D360/45.2។

[33] អ៊ីមែលពីក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង ទៅសហព្រះរាជអាជ្ញា សហមេធាវីការពារក្ដី អោ អាន ចៅក្រមអង្គបុរេជំនុំជម្រះ ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០២០។

[34] សារណាស្ដីពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញតាមវិធាន ៨០ របស់ អោ អាន ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់ I និងសារណាតបទៅនឹងសារណាស្ដីពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញតាមវិធាន ៨០ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២០។ *សូមមើលផងដែរ* អ៊ីមែលជូនដំណឹងពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់ អោ អាន ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២០។

ពិចារណារបស់អង្គបុរេជំនុំជម្រះទៅអង្គជំនុំជម្រះសាលាដំបូង[35] និងមួយទៀត បង្គាប់មិនឱ្យជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែឱ្យរក្សាទុកសំណុំរឿងនេះជំនួសវិញ[36]។

19. នៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០ ប្រធានអង្គបុរេជំនុំជម្រះបានបញ្ជូនអនុស្សរណៈអន្តរការិយាល័យទៅប្រធានផ្នែកគ្រប់គ្រងតុលាការ ដោយបានចម្លងជូនចៅក្រមអង្គបុរេជំនុំជម្រះ និងប្រធានការិយាល័យរដ្ឋបាល និងដោយបានបញ្ជាក់ថា "មតិផ្ទាល់ខ្លួន និងសេចក្តីសម្រេចរបស់ចៅក្រមផ្សេងៗ ពុំមានអានុភាពជាធរមាន [...] និងការជូនដំណឹងទៅបុគ្គលណាមួយ ឬអង្គជំនុំជម្រះណាមួយ ដែលពុំមែនជាភាគីនៃសំណុំរឿង គឺជាការរំលោភបំពានលើសេចក្តីសម្រេច*ជាឯកច្ឆន្ទ*របស់អង្គបុរេជំនុំជម្រះ"[37]។ នៅថ្ងៃដដែល ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានបញ្ជូនអនុស្សរណៈមួយទៅការិយាល័យរដ្ឋបាល និងផ្នែកគ្រប់គ្រងតុលាការ ចម្លងជូនប្រធានអង្គបុរេជំនុំជម្រះ និងចៅក្រមជាតិ ដោយបញ្ជាក់ថា សិទ្ធិអំណាចរបស់ប្រធានតាមវិធាន ៧៧ នៃវិធានផ្ទៃក្នុង ពុំបានអនុញ្ញាតឱ្យបង្គាប់ទៅផ្នែកគ្រប់គ្រងតុលាការ និងថា ប្រធានបានអនុវត្តបំពានលើក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក.[38]។ ចៅក្រមអន្តរជាតិបានបញ្ជាក់ជាថ្មីថា មតិភាគច្រើនលើសលុប ពុំអាចរកបានក្នុងការបដិសេធដីកាចោទប្រកាន់ ដូច្នេះដីកានេះចាត់ទុកជាបានការ តម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលសំណុំរឿង ០០៤/២ ដោយអនុលោមតាមវិធាន ៧៧(១៣)(ខ)។ អាស្រ័យហេតុនេះ ចៅក្រមអន្តរជាតិបង្គាប់ការិយាល័យឱ្យជូនដំណឹងអង្គជំនុំជម្រះសាលាដំបូងនូវ*សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ*[39]។ ចៅក្រមអន្តរជាតិបានបន្ថែមទៀតថា ការជូនដំណឹងគឺជាការចាំបាច់

---

[35] ឯកសារភ្ជាប់ទី ៤ នៃអនុស្សរណៈចុះថ្ងៃទី ១២ ខែ មីនា ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២០ ឯកសារលេខ D359/36.4 និង D369/45.4។

[36] ឯកសារភ្ជាប់ទី ៣ នៃអនុស្សរណៈចុះថ្ងៃទី ១២ ខែ មីនា ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២០ ឯកសារលេខ D359.24 និង D360.33។

[37] ឯកសារភ្ជាប់ទី ៥ នៃអនុស្សរណៈចុះថ្ងៃទី ១២ ខែ មីនា ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០ ឯកសារលេខ D359/36.5 និង D360/45.6 ទំព័រ ២។ *សូមមើល* អនុស្សរណៈរបស់ប្រធានពាក់ព័ន្ធទៅនឹងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០ ឯកសារលេខ D359/34 & D360/43។

[38] ឯកសារភ្ជាប់ទី ៦ នៃអនុស្សរណៈចុះថ្ងៃទី ១២ ខែ មីនា ឯកសារលេខ D359/36.6 និង D360/45.6 ទំព័រ ១ ដល់ ៣ និង ៥។ *សូមមើលផងដែរ* អនុស្សរណៈរបស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះពាក់ព័ន្ធទៅនឹងការជូនដំណឹងនៃសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០ ឯកសារលេខ D359/35 និង D360/44។

[39] អនុស្សរណៈរបស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០ ឯកសារលេខ D359/35 និង D360/44 ទំព័រ ៥ ដល់ ៦។

"ដើម្បីរារាំងនូវស្ថានភាពនៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលមិនអាចអនុវត្តបាន និងរឿងក្តីដែលកំពុងជាប់គាំង" ហើយក្នុងករណីពុំមានការជូនដំណឹង អង្គជំនុំជម្រះសាលាដំបូង"ទំនងជាស្ថិតក្នុងកាលៈទេសៈពិសេស ដែលខ្លួនពុំត្រូវបានអនុញ្ញាតចូលមើលសំណុំរឿង និងពុំអាចដោះស្រាយលើសំណើនៅចំពោះមុខ"។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះក៏បានបញ្ជាក់ថា វាពុំអាចទៅរួចសម្រាប់អង្គជំនុំជម្រះនៃ អ.វ.ត.ក. ធ្វើចំណាត់ការតាមផ្លូវតុលាការបាន នៅពេលដែលអង្គជំនុំជម្រះនោះមានភាពផ្ទុយគ្នាលើភាពចាំបាច់ក្នុងការធ្វើដូច្នោះ[40]។

20. នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០២០ ការិយាល័យរដ្ឋបាលបានផ្ញើអនុស្សរណៈទៅកាន់ប្រធានអង្គបុរេជំនុំជម្រះ ចម្លងជូនចៅក្រម និងស្នើសុំ"ការបំភ្លឺដែលមានអានុភាពផ្លូវច្បាប់"លើបញ្ហាថា តើផ្នែកបណ្ណសារ និងកត់ត្រាគប្បីអនុវត្តដូចម្តេចចំពោះការបង្គាប់ផ្ទុយគ្នារបស់ក្រឡាបញ្ជី ឬជាជម្រើសផ្តល់ការបង្គាប់ដែលអាចធ្វើចំណាត់ការបាន[41]។ រហូតមកដល់ពេលនេះ ពុំមានការឆ្លើយតបចំពោះអនុស្សរណៈនេះនៅឡើយ។

21. នៅថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំទៅអង្គជំនុំជម្រះសាលាដំបូងឱ្យប្រាប់ទៅអង្គបុរេជំនុំជម្រះឱ្យចាត់វិធានការផ្នែករដ្ឋបាលចាំបាច់ទាំងអស់សម្រាប់ការបញ្ជូនបន្ទាន់នូវដីកាចោទប្រកាន់ និងសំណុំរឿង[42]។ នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២០ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង បានទទួលស្គាល់ថា បានទទួលសំណើនេះតាមរយៈអ៊ីមែល[43]។

---

[40] អនុស្សរណៈរបស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះពាក់ព័ន្ធទៅនឹងការជូនដំណឹងនៃសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០ ឯកសារលេខ D359/35 និង D360/44។

[41] ឯកសារភ្ជាប់ទី ៧ នៃអនុស្សរណៈចុះថ្ងៃទី ១២ ខែ មីនា ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០២០ ឯកសារលេខ D359/36.7 និង D360/45.7។

[42] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំថា អង្គជំនុំជម្រះសាលាដំបូងធ្វើចំណាត់ទទួលដីកាបញ្ជូនរឿងទៅជំនុំជម្រះសំណុំរឿង ០០៤/២ (អោ អាន) និងសំណុំរឿងថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០២០ (ឧបសម្ព័ន្ធ U1 (ភាសាអង់គ្លេស) និង U2 (ខ្មែរ))។

[43] ឯកសារភ្ជាប់ទី ៨ នៃអនុស្សរណៈចុះថ្ងៃទី ១២ ខែ មីនា អ៊ីមែលផ្ញើពីក្រឡាបញ្ជី និងមន្ត្រីច្បាប់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២០ ឯកសារលេខ D359/36.8 និង 360/45.8។

22. នៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជូនអនុស្សរណៈទៅការិយាល័យរដ្ឋបាល ស្នើសុំឱ្យចាត់វិធានការបន្ទាន់បញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងដោយអនុវត្ត*តាមសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ* និង វិធានផ្ទៃក្នុង[44]។ នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២០ ការិយាល័យរដ្ឋបាលបានឆ្លើយតបថា ខ្លួនអាចត្រឹមតែអនុវត្តតាមការបង្គាប់របស់អង្គជំនុំជម្រះពាក់ព័ន្ធប៉ុណ្ណោះ[45]។

23. នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២០ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីតាមរយៈអ៊ីមែលថា បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានដឹងអំពី*សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ*ក៏ដោយ ក៏ខ្លួន*នៅតែ*ពុំបានទទួលការជូនដំណឹងជាផ្លូវការអំពីសេចក្តីពិចារណានេះ ក៏ដូចជាសំណុំរឿងដែរ ដោយសារអង្គបុរេជំនុំជម្រះ ត្រូវផ្តួចផ្តើមមុនគេនូវសកម្មភាពទាំងនោះ[46]។ នៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំការបំភ្លឺអំពីអ៊ីមែលនេះពីអង្គជំនុំជម្រះសាលាដំបូង និងបានស្នើសុំឱ្យដាក់ផ្សាយជាសាធារណៈនូវការដាក់ឯកសារនៃសំណុំរឿង ០០៤/២ ដើម្បីធានានូវតម្លាភាពនៃកិច្ចដំណើរការនីតិវិធី[47]។ ពុំមានការបំភ្លឺណាមួយត្រូវបានផ្តល់ដោយអង្គជំនុំជម្រះសាលាដំបូងឡើយ។

---

[44] អនុស្សរណៈអន្តរការិយាល័យ"សំណើសុំចំណាត់ការរដ្ឋបាលស្របតាមសំណុំរឿង ០០៤/២" ឯកសារលេខ D359/24 និង D360/33 សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៩ របស់សហព្រះរាជអាជ្ញាអន្តរជាតិ Brenda J. Hollis ទៅប្រធានស្តីទី Tony Kranh និងអនុប្រធានការិយាល័យរដ្ឋបាល Knut Rosandhaug ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០២០។

[45] អនុស្សរណៈអន្តរការិយាល័យ"អនុស្សរណៈថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០២០ ពាក់ព័ន្ធនឹងសំណុំរឿង ០០៤/២"ពីឯកឧត្តម Tony Kranh ប្រធានស្តីទី និងអនុប្រធានការិយាល័យរដ្ឋបាល Knut Rosandhaug ទៅសហព្រះរាជអាជ្ញាអន្តរជាតិ Brenda J. Hollis ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២០។

[46] អ៊ីមែលពីក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង(ចម្លងជូនទៅក្រុមអង្គបុរេជំនុំជម្រះ និងប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល) ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២០ ឯកសារលេខ D359/36.8 និង 360/45.8។

[47] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំការបំភ្លឺនៃអ៊ីមែលរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២០ (ភ្ជាប់ឧបសម្ព័ន្ធសាធារណៈ A-F) ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០២០។

24. នៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២០ ការបកប្រែជាភាសាខ្មែរនៃសេចក្ដីសង្ខេបអំពីអញ្ញត្រកម្មបឋមរបស់ អោ អាន ត្រូវបានបញ្ជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ[48] ដែលបានដាក់ការឆ្លើយតបនៅអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២០[49]។

25. នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២០ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានបញ្ជូនអនុស្សរណៈអន្តរការិយាល័យមួយទៅភាគីទាំងអស់នៃរឿងក្ដី ០០៤/២ រៀបរាប់លម្អិតអំពីភាពជាប់គាំងដំណើរការផ្នែករដ្ឋបាល និងតុលាការរវាងអង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល។ ចៅក្រមអន្តរជាតិបានកត់សម្គាល់ថា ការបង្គាប់ពីរផ្ទុយគ្នា ត្រូវបានផ្ញើទៅផ្នែកបណ្ណសារ និងកត់ត្រា ដោយអង្គបុរេជំនុំជម្រះ៖ តាមរយៈក្រឡាបញ្ជី បានណែនាំផ្នែកបណ្ណសារ និងកត់ត្រា ឱ្យជូនដំណឹងជាផ្លូវការដល់អង្គជំនុំជម្រះសាលាដំបូង ខណៈដែលចៅក្រមជាតិ តាមរយៈក្រឡាបញ្ជីផ្សេងទៀត បានបង្គាប់ផ្នែកបណ្ណសារ និងកត់ត្រា មិនឱ្យជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែត្រូវរក្សាទុកក្នុងបណ្ណសារ។ ចៅក្រមអន្តរជាតិបានបញ្ជាក់ថា ខ្លួនបានធ្វើអស់ពីលទ្ធភាព និងថា កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបានដល់ទីបញ្ចប់ហើយ[50]។ អ៊ីមែលត្រូវបានចម្លងជូនទៅចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ និងក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង។

26. នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២០ ប្រធានអង្គបុរេជំនុំជម្រះបានចេញអនុស្សរណៈអន្តរការិយាល័យមួយទៅភាគីដោយបានបញ្ជាក់ថា អង្គជំនុំជម្រះ“បានបំពេញកាតព្វកិច្ចរួចរាល់ហើយ” និងពុំតម្រូវឱ្យចាត់វិធានការផ្នែករដ្ឋបាលបន្ថែមទៀតនោះទេ។ ប្រធានអង្គបុរេជំនុំជម្រះបានបញ្ជាក់ថា មានតែផ្នែកនៃសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះដែលទទួលបានការសម្រេចជាឯកច្ឆន្ទប៉ុណ្ណោះ “មានអានុភាពជាធរមាន” និងថា មតិរបស់ចៅក្រមជាតិ និងអន្តរជាតិ គឺជា“មតិផ្ទាល់ខ្លួន” ពុំមាន“អានុភាពជាធរមាន”ឡើយ។

---

[48] អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់ អោ អាន “ការផ្ញើជូនជាការគួរសមនូវការបកប្រែជាភាសាខ្មែរនៃសេចក្ដីសង្ខេបអញ្ញត្រកម្មបឋមរបស់ អោ អាន” ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២០។

[49] សារណាតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្ដីសង្ខេបអញ្ញត្រកម្មបឋមរបស់ អោ អាន តាមវិធាន ៨៩(១) ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២០។

[50] អនុស្សរណៈអន្តរការិយាល័យពីចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ“ការបញ្ជូនសំណុំរឿង ០០៤/២” ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០២០ ឯកសារលេខ D359/36 និង D360/45។

ប្រធានបានបញ្ជាក់ថា អង្គបុរេជំនុំជម្រះនឹងពុំចាត់វិធានការផ្នែករដ្ឋបាលបន្ថែមក្នុងការជូនដំណឹងអង្គជំនុំជម្រះសាលាដំបូង ឬបញ្ជូនសំណុំរឿងនោះទេ[51]។

27. នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំបីរូបក្នុងសំណុំរឿង ០០៤/២ បានដាក់សំណើសុំអង្គបុរេជំនុំជម្រះចាត់វិធានការចាំបាច់នានា ដើម្បីធានាដល់សិទ្ធិរបស់ភាគីក្នុងសំណុំរឿង ០០៤/២[52]។

28. នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំបន្តទៀតដល់អង្គជំនុំជម្រះសាលាដំបូងឱ្យដំណើរការសំណើរឿង ០០៤/២[53]។ នៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២០ អោ អាន បានឆ្លើយតបថា គាត់ពុំបានចាត់ទុកថា អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០៤/២ ត្រឹមត្រូវតាមច្បាប់នោះទេ និងថា អង្គជំនុំជម្រះសាលាដំបូងខ្វះយុត្តាធិការក្នុងការជំនុំជម្រះលើសំណើបន្តនោះ[54]។

29. នៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០២០ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីប្រកាសព័ត៌មាន[55] ដែលក្នុងនោះ អង្គជំនុំជម្រះបានកត់សម្គាល់ថា "អង្គជំនុំជម្រះពុំមានសំណុំរឿង និងពុំអាចចូលមើលសំណុំរឿងបាន ដរាបណា និងទាល់តែ មានការជូនដំណឹង និងការបញ្ជូនត្រឹមត្រូវនៃសំណុំរឿងនេះ" និងបាន

[51] អនុស្សរណៈរបស់ប្រធាន ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២០ ឯកសារលេខ D359/37 និង D360/46។

[52] សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំវិធានការចាំបាច់ត្រូវធ្វើឡើងដោយអង្គបុរេជំនុំជម្រះក្នុងការការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០៤/២ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ឯកសារលេខ D359/33 និង D360/42។

[53] សំណើសាជាថ្មីរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅអង្គជំនុំជម្រះសាលាដំបូងសុំឱ្យធ្វើចំណាត់ការបន្តជំនុំជម្រះសំណុំរឿង ០០៤/២ រួមបញ្ចូលការបង្គាប់ឱ្យបញ្ជូនភ្លាមៗនៃសំណុំរឿង ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ("ឧបសម្ព័ន្ធ X1 (ភាសាអង់គ្លេស) X2 (ខ្មែរ)")។

[54] សារណាតបទៅនឹងសំណើសុំសាជាថ្មីរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅអង្គជំនុំជម្រះសាលាដំបូងចាត់វិធានការចាំបាច់បន្តជំនុំជម្រះសំណុំរឿង ០០៤/២ រួមបញ្ចូលការបង្គាប់ការបញ្ជូនភ្លាមៗនូវសំណុំរឿង ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២០។

[55] សេចក្តីបញ្ជាក់របស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក. ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០៤/២ លើ អោ អាន ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០២០ ("សេចក្តីប្រកាសព័ត៌មានថ្ងៃទី ០៣ ខែ មេសា" ឬ"សេចក្តីប្រកាសព័ត៌មាន") ("ភ្ជាប់នៅក្នុងតារាងសំអាងផ្លូវច្បាប់ 16A (អង់គ្លេស) និង 16B (ខ្មែរ)")។ *សូមមើលផងដែរ* អ៊ីមែលពីក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង "អ៊ីមែលរបស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០២០ ("ឧបសម្ព័ន្ធ H"): https://www.eccc.gov.kh/en/articles/statement-judges-trial-chamber-eccc-regarding-case-0042-involving-ao.

បញ្ជាក់*ក្នុងចំណោមនោះ*ថា ការចេញសេចក្តីសម្រេចផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូង គឺ"ពុំអាចទៅរួចឡើយ"។ អង្គជំនុំជម្រះបានកត់សម្គាល់បន្ថែមទៀតថា សេចក្តីប្រកាសព័ត៌មាន"ពុំមានអានុភាពផ្លូវច្បាប់" ប៉ុន្តែក្នុងគោលបំណងផ្តល់តម្លាភាព និងការបំភ្លឺដល់ភាគី និងមហាជន។ ដោយសារចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងបានពន្យល់ពីជំនឿរបស់ខ្លួនថា "អំណះអំណាងគប្បីលើកឡើងថា ក្រោមកាលៈទេសៈពិសេសនៃរឿងក្តី អង្គជំនុំជម្រះសាលាដំបូងមាន*សិទ្ធិអំណាចនៃឆន្ទានុសិទ្ធិ*ដោះស្រាយបញ្ហាបឋមមួយចំនួនដែលលើកឡើងដោយភាគី" ចៅក្រមជាតិបានជូនដំណឹងភាគីថា រាល់ឯកសារទាំងអស់ និងសំណើដែលបានដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នឹងត្រូវបង្វិលត្រឡប់ទៅវិញ ដោយប្រកាសថា "ពុំមានការជំនុំជម្រះលើ អោ អាន ពេលបច្ចុប្បន្ន ឬក្នុងពេលអនាគត"។ នៅថ្ងៃដដែល ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានផ្ញើសេចក្តីប្រកាសព័ត៌មានដល់ភាគី[56]។

30. នៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០ ឯកសារដែលបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិនៅអង្គជំនុំជម្រះសាលាដំបូង ត្រូវបានបង្វិលត្រឡប់ទៅវិញដោយដាក់ថា "បញ្ជូនត្រឡប់ទៅម្ចាស់ដើមវិញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០"[57]។

31. នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងសាទុក្ខភ្លាមៗ[58]។ នៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០២០ អោ អាន បានដាក់សារណាតប[59] និងនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ការឆ្លើយតប[60]។

---

[56] សេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី ០៣ ខែ មេសា ទំព័រ ២។

[57] អ៊ីមែលផ្ញើទៅការិយាល័យសហព្រះរាជអាជ្ញា"ឯកសារដាក់ជាច្បាប់ចម្លងទៅអង្គជំនុំជម្រះសាលដំបូង ឯកសារលេខ CF004/2 ត្រូវបានបង្វិលត្រឡប់មកការិយាល័យសហព្រះរាជអាជ្ញានៅរសៀលនេះ" ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០។ *សូមមើលផងដែរ* ការទទួលបាន"ការបង្វិលទៅម្ចាស់ដើម" នៃការដាក់ឯកសារពីអង្គជំនុំជម្រះសាលាដំបូង ទៅសហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០២០។

[58] បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០ ឯកសារលេខ E004/2/1 ជូនដំណឹងនៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២០។

[59] សារណាតបរបស់ អោ អាន ទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ បានបញ្ជូននៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០២០ ឯកសារលេខ E004/2/1/1 ជូនដំណឹងនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០ ("សារណាតប")។

32. នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០២០ មាស មុត (សំណុំរឿង ០០៣) បានដាក់សំណើសុំការអនុញ្ញាតអន្តរាគមន៍ និងឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗ[61]ដោយផ្អែកលើមូលដ្ឋានថា បណ្តឹងនេះនឹងចៀសពុំរួចធ្វើឱ្យប៉ះពាល់ដល់រឿងក្តីរបស់ខ្លួន និងនៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០២០ យឹម ទិត្យ (សំណុំរឿង ០០៤) ក៏បានដាក់សំណើដូចគ្នាផងដែរដោយបានអះអាងថា ខ្លួនមានអត្ថប្រយោជន៍ត្រឹមត្រូវក្នុងការចូលអន្តរាគមន៍ក្នុងសំណុំរឿង ០០៤/២[62]។ នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២០ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបដិសេធសំណើទាំងពីរនេះ[63]។

33. នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីភាពអាចទទួលបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវចូលរួមសវនាការ និង/ឬតំណាងក្នុងសំណុំរឿងពាក់ព័ន្ធទៅនឹង អោ អាន ដែលក្នុងនោះមតិភាគច្រើនលើសលុបពុំអាចរកបាន[64]។ បន្ថែមលើមតិនីមួយៗរបស់ខ្លួន ចៅក្រមជាតិបានយល់ឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤/២ ត្រូវបានបដិសេធចោល

---

[60] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងលិខិតរបស់ អោ អាន ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E004/2/1/1/1 ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០ ("ការឆ្លើយតប")។

[61] សំណើរបស់ មាស មុត សុំការអនុញ្ញាតធ្វើអន្តរាគមន៍ និងឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E004/2/2 ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០២០។

[62] សំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតធ្វើអន្តរាគមន៍ក្នុងសំណុំរឿង ០០៤/២ ស្តីពីយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល ឯកសារលេខ E004/2/3 ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០២០។

[63] សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំការអនុញ្ញាតធ្វើអន្តរាគមន៍ និងឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E004/2/2/1 ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២០។ សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំការអនុញ្ញាតធ្វើអន្តរាគមន៍ក្នុងសំណុំរឿង ០០៤/២ ស្តីពីយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល ឯកសារលេខ E004/2/4/1 ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២០។

[64] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបង្គាប់ស្តីពីភាពអាចទទួលយកបាននូវអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០ ឯកសារលេខ D362/6 *សូមមើល*ផ្នែកសម្រេចសេចក្តី លេខ ERN 01647370។

[65] ខណៈដែលចៅក្រមអន្តរជាតិយល់ឃើញថា "ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលត្រូវបានយល់ឃើញថាអាចទទួលយកបានដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពេលអនាគតប្រឆាំងនឹង អោ អាន"[66]។

## គ. បណ្តឹងសាទុក្ខភ្លាមៗ

34. សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យ ទទួលយកបណ្តឹងសាទុក្ខភ្លាមៗ និងយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០៤/២ និងបង្គាប់ថា ចំណាត់ការផ្នែករដ្ឋបាលត្រូវធ្វើឡើងដើម្បីធានាថា រឿងក្តីនេះបន្តដំណើរការទៅជំនុំជម្រះ។ ជាពិសេស សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំការពិចារណាលើបញ្ហាដូចខាងក្រោម៖

*ក. ភាពអាចទទួលយកបានតាមទម្រង់*

(i) ទទួលយកបណ្តឹងសាទុក្ខភ្លាមៗ ដោយអនុលោមតាមវិធាន ១០៤(៤)(ក) និងចាត់ទុកថា អង្គជំនុំជម្រះសាលាដំបូងបានទទួលត្រឹមត្រូវតាមច្បាប់នូវសំណុំរឿង ០០៤/២ ដោយផ្អែកលើមូលដ្ឋានថា៖

(ក) ភាពអសកម្មរបស់អង្គជំនុំជម្រះសាលាដំបូង រួមទាំងការខកខានក្នុងការអនុញ្ញាត និងជូនដំណឹង ព្រមទាំងការបង្វិលត្រឡប់មកវិញនូវការដាក់ឯកសារទាំងអស់ក្នុងសំណុំរឿង ០០៤/២ អាចស្មើនឹងអំពើដែលបញ្ចប់អានុភាពនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/២ ប្រឆាំងនឹង អោ អាន

(ខ) សេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី ០៣ ខែ មេសា របស់អង្គជំនុំជម្រះសាលាដំបូង គឺជាសេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខបាននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

(ii) ជាជម្រើស សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលប្រើប្រាស់យុត្តាធិការដែលជាឆន្ទានុសិទ្ធិ និងកំណត់បណ្តឹងសាទុក្ខភ្លាមៗនេះ។

*ខ. ថា អង្គជំនុំជម្រះតុលាការកំពូល*

(i) បង្គាប់ឱ្យបញ្ជូនសំណុំរឿង ០០៤/២ ទៅអង្គជំនុំជម្រះសាលាដំបូង សម្រាប់គោលបំណងបណ្តឹងសាទុក្ខនេះ

(ii) យល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០៤/២ និងបង្គាប់ថា ចំណាត់ការផ្នែករដ្ឋបាលត្រូវធ្វើឡើងដើម្បីធានាថា អង្គជំនុំជម្រះស្តាប់រឿងក្តីនេះ

(iii) ទទួលស្គាល់ការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញាអន្តរជាតិ និងជនរងគ្រោះ

---

[65] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០ ឯកសារលេខ D362/6 ERN 01647371 កថាខណ្ឌ ៤១ ដល់ ៤៣។

[66] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០ ឯកសារលេខ D362/6 ERN 01647400 កថាខណ្ឌ ១១៨។

(iv) ចេញដីកាបង្គាប់លើការសម្រេចតាមផ្លូវតុលាការនូវការដាក់ឯកសារមុនៗ ដែលបានបង្ហិលដោយអង្គជំនុំជម្រះសាលាដំបូង ដោយស្របតាមច្បាប់ និង

(v) ចេញជាសាធារណៈនូវសំអាងហេតុពេញលេញ និងផ្តល់នូវភាពប្រាកដប្រជាផ្លូវច្បាប់ និងស្មារមុខនាទីរបស់តុលាការ។

## ឃ. បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ

35. អនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី បើកផ្លូវឱ្យធ្វើបណ្តឹងសាទុក្ខភ្លាមៗ។

36. ស្របតាមបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេច ដែលបានកំណត់ក្នុងវិធាន ១០៤(១) និង ១០៥(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចបណ្តឹងសាទុក្ខភ្លាមៗដោយផ្អែកលើមូលដ្ឋានដូចតទៅ៖ (ក) កំហុសលើអង្គច្បាប់ដែលនាំឱ្យមោឃៈសេចក្តីសម្រេចនោះ (ខ) កំហុសអង្គហេតុដែលនាំឱ្យមានភាពមិនយុត្តិធម៌ ឬ (គ) កំហុសដែលស្តែងចេញពីការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំឱ្យប៉ះពាល់ដល់សិទ្ធិម្ចាស់បណ្តឹងសាទុក្ខ(សហព្រះរាជអាជ្ញាអន្តរជាតិ)។

## ង. កំណត់សម្គាល់បឋម

37. យោងតាមវិធាន ១០៨(៤) *ស្ទួន* (ខ)៖

> "អង្គជំនុំជម្រះតុលាការកំពូលត្រូវចេញសេចក្តីសម្រេចរបស់ខ្លួនស្តីពីបណ្តឹងសាទុក្ខភ្លាមៗ (ខ) ប្រឆាំងនឹងសេចក្តីសម្រេចដែលបានធ្វើឡើងដោយស្របតាមវិធាន ១០៤(៤)(ក) ក្នុងរយៈពេលបីខែ បន្ទាប់ពីបានទទួលឯកសារដូចមានចែងក្នុងកថាខណ្ឌ ២ នៃវិធាននេះ។ ប៉ុន្តែក្នុងករណីពិសេស អង្គជំនុំជម្រះតុលាការកំពូលអាចពន្យារថេរវេលាមួយខែបន្ថែមទៀត។ ប្រសិនបើសេចក្តីសម្រេចនេះ មិនត្រូវបានចេញក្នុងរយៈពេលកំណត់នោះទេ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវចាត់ទុកជាបានការ [...]"

38. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ដោយសារកាលៈទេសៈខុសពីធម្មតាដែលនាំឱ្យមានការពន្យារពេលក្នុងការដាក់បណ្តឹងសាទុក្ខភ្លាមៗ និងសារណាតប បណ្តឹងសាទុក្ខនេះបានដាក់នៅថ្ងៃទី ០៤ ខែ ឧសភា និងបានជូនដំណឹងនៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២០ ខណៈពេលដែលសារណាតបត្រូវបានបញ្ជូនតាមរយៈអ៊ីមែលនៅថ្ងៃទី ១៤ ខែ ឧសភា និងជូនដំណឹងជាផ្លូវការនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ

២០២០ ដូចគ្នានឹងការឆ្លើយតបដែរ។ ការពន្យារពេលនេះកើតឡើងដោយសារភាពស្មុគស្មាញ ហើយបញ្ហាសារវន្តនៃបណ្តឹងសាទុក្ខភ្លាមៗនេះ បានតម្រូវឱ្យមានភាពចាំបាច់ក្នុងការពន្យារពេលមួយខែបន្ថែមទៀតសម្រាប់ការចេញសេចក្តីសម្រេចដោយផ្អែកលើវិធាន ១០៨(៤) *ស្ទួន* (ខ) ខាងលើ។

39. សហព្រះរាជអាជ្ញាអន្តរជាតិបានជំទាស់ទៅនឹងសារណាតបរបស់ អោ អាន ដែលបានដាក់ក្នុងទម្រង់ជាលិខិតមួយច្បាប់ និងបានអះអាងថា សារណាតបនេះពុំស្របតាមទម្រង់បែបបទនៃការដាក់សារណាផ្លូវការដូចមានចែងក្នុងសេចក្តីណែនាំអនុវត្ត[67]។ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិជាអាសារបង់ ដោយសារសារណាតបជាលទ្ធផលត្រូវបានដាក់ និងជូនដំណឹងត្រឹមត្រូវដែលសហព្រះរាជអាជ្ញាខ្លួនឯងក៏បានធ្វើការឆ្លើយតបផងនោះ[68]។

## ច. ភាពអាចទទួលយកបានតាមទម្រង់

40. សហព្រះរាជអាជ្ញាអន្តរជាតិបានផ្អែកអំណះអំណាងរបស់ខ្លួនលើមូលដ្ឋានពីរជាជម្រើសក្នុងការគាំទ្រសំណើសុំទទួលយកបណ្តឹងសាទុក្ខភ្លាមៗនេះ។ ទីមួយ សហព្រះរាជអាជ្ញាបានផ្អែកលើវិធាន ១០៤(៤)(ក) និងទីពីរថា អង្គជំនុំជម្រះសម្រេចបណ្តឹងសាទុក្ខដោយផ្អែកលើយុត្តាធិការឆន្ទានុសិទ្ធិរបស់ខ្លួន។

### *សារណារបស់ភាគី*

41. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០៤/២ ត្រឹមត្រូវតាមច្បាប់ ដោយហេតុថា ពុំមានសេចក្តីសម្រេចដែលតម្រូវឱ្យមានមតិភាគច្រើនលើសលុបជំទាស់ទៅនឹងដីកាចោទប្រកាន់ឡើយ។ ជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលដូចគ្នាទៅនឹងចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះដែរ គឺថា ដោយអនុលោមតាមវិធាន ៧៧(១៣)(ខ) ករណីដែលមិនអាចរកសម្លេងភាគច្រើនបានទេ ត្រូវសម្រេចបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង[69] និងជាលទ្ធផល កិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់នៅទីនោះ។ សហព្រះរាជអាជ្ញាបានអះអាងថា អំពើអសកម្មរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់ការដាក់ឯកសារដែលបានធ្វើឡើងក្នុងសំណុំរឿង ០០៤/២ បន្ទាប់ពីការ

---

[67] ការឆ្លើយតប កថាខណ្ឌ ២។

[68] សារណាតប។

[69] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៥០។

ចេញ*សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ* និងសកម្មភាពបន្តបន្ទាប់ក្នុងការបង្វិលឯកសារទាំងអស់រួមជាមួយនឹងសេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី ៣ ខែ មេសា ទាំងអស់នេះបង្កើតបានជាសេចក្តីសម្រេចដែលបើកផ្លូវឱ្យប្តឹងសាទុក្ខបាន។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អំពើអសកម្មរបស់អង្គជំនុំជម្រះសាលាដំបូងស្មើទៅនឹងសេចក្តីសម្រេចដែលស្ថិតក្រោមអត្ថន័យនៃវិធាន ១០៤(៤)(ក)[70]។

42. ជាជម្រើស សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ជាផលវិបាកនៃអំពើអសកម្មរបស់អង្គជំនុំជម្រះសាលាដំបូង និងសេចក្តីប្រកាសព័ត៌មានចុះថ្ងៃទី ០៣ ខែ មេសា ដែល*ក្នុងចំណោមនោះ* អង្គជំនុំជម្រះបានសន្និដ្ឋានថា ខ្លួនពុំមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេច*ណាមួយ*ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០៤/២[71] និងបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលប្រើប្រាស់យុត្តាធិការឆន្ទានុសិទ្ធិសម្រេចលើបញ្ហា ដែលអាចសម្រេចបានដោយតុលាការ ដោយសារអង្គជំនុំជម្រះ*ពេលបច្ចុប្បន្ន*គឺជាស្ថាប័នដែលអាចរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងការពារអត្ថប្រយោជន៍យុត្តិធម៌។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលបដិសេធធ្វើអន្តរាគមន៍ សិទ្ធិបណ្តឹងសាទុក្ខប្រែទៅជាគ្មានន័យ ដោយដាក់ភាគី"ស្ថិតក្នុងរឿងក្តីដែលមិនដំណើរការសមស្រប និងគ្មានដំណោះស្រាយ"[72]។ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា យុត្តិសាស្ត្រដែលមានសំអាងហេតុពេញលេញ គឺជាការចាំបាច់ ដោយសារកាលៈទេសៈនៃនីតិវិធីប្រហាក់ប្រហែលគ្នាដែលមានសក្តានុពលទំនងជានឹងមានអត្ថិភាពក្នុងរឿងក្តី ០០៣ និង ០០៤[73]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវស្តាប់បណ្តឹងសាទុក្ខភ្លាមៗនេះ ស្របតាមយុត្តាធិការនៃឆន្ទានុសិទ្ធិរបស់ខ្លួន "ក្នុងការសម្រេចបញ្ហាគតិយុត្តិនៅចំពោះមុខប្រកបដោយភាពច្បាស់លាស់" "ដោះស្រាយបញ្ហាអង្គសេចក្តី និង/ឬនីតិវិធី និង"ធានារដ្ឋបាលតុលាការល្អ និងយុត្តិធម៌"[74]។

43. អោ អាន បានឆ្លើយតបថា បណ្តឹងសាទុក្ខភ្លាមៗនេះពុំអាចទទួលយកបាន ដោយសារពុំមែនជាបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្របតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង និងអះអាងថា បណ្តឹងសាទុក្ខភ្លាមៗជាក់ស្តែងគឺប្រឆាំងនឹងសេចក្តីប្រកាសព័ត៌មាន ដែល

---

[70] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤១ ដល់ ៤៥។

[71] សេចក្តីប្រកាសព័ត៌មានថ្ងៃទី ០៣ ខែ មេសា។

[72] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤៨។

[73] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤៨ ៥៨ ដល់ ៦១។

[74] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤៦ ដល់ ៤៩។

ថៅក្រុមអង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សម្គាល់ថា "ពុំមានអានុភាពផ្នែកគតិយុត្តិ" ដូច្នេះ ពុំមែនជាសកម្មភាពរបស់តុលាការដែលមានអានុភាពផ្លូវច្បាប់ដូចជាសេចក្តីសម្រេចឡើយ[75]។ អោ អាន បានសំអាងទៅលើសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ដែលគូសបញ្ជាក់នូវអ្វីដែលជាសេចក្តីសម្រេច និងបានលើកឡើងថា ដោយសារសេចក្តីប្រកាសព័ត៌មានជាលាយលក្ខណ៍អក្សរ អង្គជំនុំជម្រះពុំអាចសម្រេចលើបញ្ហាគតិយុត្តិចំពោះមុខខ្លួនបានដោយច្បាស់លាស់នោះទេ ឬបើទោះបីមានផ្នែកខ្លះមានអានុភាពច្បាប់ក៏ដោយ [...] ឬដោះស្រាយលើបញ្ហាអង្គសេចក្តី និង/ឬនីតិវិធីដោយបង្កើត [...] ឬផ្តល់សំអាងហេតុពេញលេញគាំទ្រសេចក្តីសន្និដ្ឋានរបស់ខ្លួនបានឡើយ[76]។ អោ អាន បានបន្ថែមថា បណ្តឹងសាទុក្ខភ្លាមៗ គឺជាការព្យាយាមរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការប្តឹងលើ *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ* ដែលពុំត្រូវបានអនុញ្ញាតតាមក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក.[77]។

44. អោ អាន បានបដិសេធការលើកឡើងរបស់សហព្រះរាជអាជ្ញាដែលថា ភាពអសកម្មរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០៤/២ និងការខកខានដែលបានចោទប្រកាន់ក្នុងការអនុញ្ញាតការដាក់ឯកសារតាមប្រព័ន្ធអេឡិចត្រូនិច និងការជូនដំណឹង និងការបង្វិលរាល់ឯកសារដែលបានដាក់ គឺជាហេតុផលពុំត្រឹមត្រូវ[78]។ ជំហររបស់ អោ អាន គឺថា ដោយសារអង្គជំនុំជម្រះសាលាដំបូងពុំបានទទួលសំណុំរឿង ០០៤/២ ត្រឹមត្រូវតាមច្បាប់ អង្គជំនុំជម្រះពុំមានកាតព្វកិច្ចចាត់ការលើរឿងក្តីនេះឡើយ។ រឿងក្តីរបស់គាត់ត្រូវបានបញ្ចប់អានុភាពចាប់តាំងពីការជូនដំណឹងអំពី *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ* អាស្រ័យ

---

[75] សារណាតប ផ្នែក ក កថាខណ្ឌ ៥ ដល់ ៦ *ដកស្រង់*សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំការអនុវត្តតាម ៣៥ នៃវិធានផ្ទៃក្នុងសម្រាប់ចំណាត់ការបន្ទាន់("សេចក្តីសម្រេចលើសំណើសុំឱ្យអនុវត្តតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង") ឯកសារលេខ E176/2/1/4 ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ កថាខណ្ឌ ២៥។

[76] សារណាតប ផ្នែក ក កថាខណ្ឌ ១ ដល់ ៣។ *ដកស្រង់* សេចក្តីសម្រេចស្តីពីការអនុវត្តន៍តាមវិធាន ៣៥ ឯកសារលេខ E176/2/1/4 ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ កថាខណ្ឌ ២៥។

[77] សារណាតប ផ្នែក ក កថាខណ្ឌ ១។

[78] សារណាតប ផ្នែក ក កថាខណ្ឌ ៥។

ហេតុនេះ បណ្ដឹងសាទុក្ខភ្លាមៗនេះ ពុំត្រឹមត្រូវតាមទម្រង់ និងពុំបានគាំទ្រការអនុវត្តន៍នូវយុត្តាធិការនៃឧន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះតុលាការកំពូលឡើយ[79]។

45. សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបថា រាល់*ការបញ្ជាក់*ទាំងអស់នៃសកម្មភាពតាមផ្លូវតុលាការដែលមានអានុភាពផ្លូវច្បាប់ជាសេចក្ដីសម្រេច ត្រូវបានបំពេញដោយការរួមបញ្ចូលគ្នានូវ (i) ភាពអសកម្មរបស់អង្គជំនុំជម្រះសាលាដំបូង (ii) ការចេញសេចក្ដីប្រកាសព័ត៌មានចុះថ្ងៃទី ០៣ ខែ មេសា បញ្ជាក់ច្បាស់ថា ភាពអសកម្មរបស់ខ្លួននឹងបន្ត និង (iii) ការបង្វិលការដាក់សារណាជាឯកសារទៅភាគីវិញ។ សហព្រះរាជអាជ្ញាអះអាងថា អំពើទាំងនេះដែលបានសម្រេចលើបញ្ហាគតិយុត្តិនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងលក្ខណៈច្បាស់លាស់ បង្ហាញដោយឥតសង្ស័យថា អង្គជំនុំជម្រះសាលាដំបូងពុំបានប្រើប្រាស់យុត្តាធិការរបស់ខ្លួនមកដោះស្រាយ កុំថាឡើយដល់ទៅអនុវត្តតាមវិធានស្ដីពីការដាក់សារណាក្នុងសំណុំរឿង ០០៤/២[80]។ សហព្រះរាជអាជ្ញាអន្តរជាតិបន្ថែមថា ការបង្វិលការដាក់ឯកសារទាំងនោះគឺជាផ្នែកសេចក្ដីសម្រេចដែលមានអានុភាពនៃ និងការចេញសេចក្ដីប្រកាសព័ត៌មានថ្ងៃទី ០៣ ខែ មេសា បានផ្ដល់សេចក្ដីសង្ខេបជាលាយលក្ខណ៍អក្សរ និងហេតុផលសម្រាប់ភាពអសកម្មរបស់ចៅក្រម[81]។ សហព្រះរាជអាជ្ញាបានបដិសេធទាំងស្រុងលើការប្រឌិតដែលថា រូបគាត់កំពុងព្យាយាមប្ដឹងសាទុក្ខទៅលើ*សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ* និងកត់សម្គាល់ថា សំណើសុំអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូល គឺត្រូវធានានូវចំណាត់ការរដ្ឋបាលសម្រាប់សំណុំរឿង ០០៤/២ ឱ្យដំណើរការទៅជំនុំជម្រះដើម្បីដោះស្រាយភាពទាល់ច្រកបច្ចុប្បន្ន[82]។

*ភាពអាចទទួលយកបានអនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង*
*ការពិភាក្សា*

46. អង្គជំនុំជម្រះតុលាការកំពូល ត្រូវប្រឈមនឹងស្ថានភាពមិនប្រក្រតីយ៉ាងខ្លាំងដូចបានគូសបញ្ជាក់យ៉ាងពេញលេញក្នុងប្រវត្តិនីតិវិធីនៃសំណុំរឿង ០០៤/២[83]។ តាមការសង្កេតបឋមបង្ហាញឱ្យដឹងច្បាស់ថា

---

[79] សារណាតប ផ្នែក ក កថាខណ្ឌ ៣។

[80] ការឆ្លើយតប កថាខណ្ឌ ៣។

[81] ការឆ្លើយតប កថាខណ្ឌ ៣។

[82] ការឆ្លើយតប កថាខណ្ឌ ៤។

[83] *សូមមើល* ប្រវត្តិនីតិវិធី *ខាងលើ*។

នេះជារឿងក្ដីដែលបានកើតឡើងនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត និងបន្ទាប់មកក្នុងអង្គបុរេជំនុំជម្រះ ដែលពុំអាចទាយដឹងទុកជាមុនដោយក្រុមអ្នកធ្វើសេចក្ដីព្រាងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក. ឬបើទោះបីអាចដឹងជាមុនក៏ដោយ ក៏ពុំត្រូវបានបញ្ជាក់ច្បាស់លាស់នៅក្នុងឯកសារជាមូលដ្ឋានដែលមានអានុភាពរបស់តុលាការឡើយ។ អង្គជំនុំជម្រះសង្កេតឃើញថា ដោយហេតុថា សហព្រះរាជអាជ្ញាអន្តរជាតិ និង អោ អាន ទំនងជាស្របគ្នាថា សំណុំរឿង ០០៤/២ កំពុងជាប់គាំងក្នុងកិច្ចដំណើរការនីតិវិធី ទើបជំទាស់ជាមូលដ្ឋានលើបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០៤/២ នេះត្រឹមត្រូវតាមច្បាប់ ដែរ ឬយ៉ាងណា។

47. អង្គជំនុំជម្រះជាដំបូងនឹងត្រូវពិចារណាលើភាពត្រឹមត្រូវតាមទម្រង់នៃបណ្ដឹងសាទុក្ខភ្លាមៗក្នុងបរិបទនៃប្រវត្តិនីតិវិធីយ៉ាងពិសេសដែលបានលើកឡើងមកនេះ[84]។ បណ្ដឹងសាទុក្ខភ្លាមៗនេះ បានដាក់ដោយអនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុងដែលធានាថា ការបើកផ្លូវឱ្យធ្វើបណ្ដឹងសាទុក្ខភ្លាមៗមានអត្ថិភាពក្នុងកាលៈទេសៈដែលកិច្ចដំណើរការនីតិវិធី ត្រូវបានបញ្ចប់ដោយពុំទាន់ឈានដល់ការចេញសាលក្រម និងផ្ដុយទៅវិញ បើសិនពុំមានវិធាននេះចែង គឺពុំមានឱកាសក្នុងការធ្វើបណ្ដឹងសាទុក្ខភ្លាមៗណាមួយឡើយ[85]។ វិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុងកន្លងមកត្រូវបានបកស្រាយដោយអង្គជំនុំជម្រះថា ត្រូវរួមបញ្ចូលសេចក្ដីសម្រេចផ្អាកកិច្ចដំណើរការនីតិវិធី ដែលពុំមានសក្ដានុពលជាក់ស្ដែងក្នុងការបន្ត ដោយ

---

[84] សិទ្ធិពិនិត្យលើបណ្ដឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការកំពូលត្រូវបានប្រើប្រាស់នៅក្នុងដែនកំណត់នៃបញ្ហាដែលបានធ្វើបណ្ដឹងសាទុក្ខ *សូមមើល* សាលដីការឿងក្ដី ឌុច កថាខណ្ឌ ១៥។

[85] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការបំបែកនីតិវិធីបន្ថែម ០០២ និងវិសាលភាពសំណុំរឿង ០០២/០២ ("បណ្ដឹងសាទុក្ខភ្លាមៗលើការបំបែកនីតិវិធីបន្ថែម") ឯកសារលេខ E301/9/1/1/3 កថាខណ្ឌ ១៧។ *សូមមើលផងដែរ* ("សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខស្ដីពីការបំបែកនីតិវិធីលើកទីពីរ") កថាខណ្ឌ ២១ និងសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០១ ឯកសារលេខ E163/5/1/13 ("សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខស្ដីពីការបំបែកនីតិវិធីលើកទីមួយ") កថាខណ្ឌ ៤៨ *យោងទៅលើ*សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកជម្លោះប្រដាប់អាវុធចេញពីលក្ខខណ្ឌតម្រូវនៃការកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ឯកសារលេខ E95/8/1/4 កថាខណ្ឌ ៩។

រារាំងការឈានទៅដល់ការចេញសាលក្រមលើអង្គសេចក្តីបាន[86]។ ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ តាមវិធាន ១០៤ និង ១០៥ នៃវិធានផ្ទៃក្នុងចែងថា យុត្តាធិការបណ្តឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការកំពូលត្រូវបានកម្រិតត្រឹមបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេច ឬសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។

48. អង្គជំនុំជម្រះចោទសំណួរថា តើសំណុំរឿង ០០៤/២ ធ្លាប់បាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែរ ឬទេ? ច្បាស់ណាស់ថា ការបកស្រាយមិនបានពេញលេញក្នុងមាត្រា ៦(៤) និង ៧(៤) នៃកិច្ចព្រមព្រៀង មាត្រា ២០ ថ្មីនៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. និងវិធាន ៧៧(១៣)(ខ) និង ៧៩(១) ក្នុងការបង្ហាញថា សំណុំរឿងអាចមកជាស្វ័យប្រវត្តិនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្រោយពីការចេញ*សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ*។ ផ្អែកតាមការបកស្រាយនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានស្វះស្វែងធ្វើកិច្ចទៅអង្គជំនុំជម្រះសាលាដំបូង ដោយផ្តួចផ្តើមដាក់សំណើមួយចំនួនសុំឱ្យរៀបចំរឿងក្តីនេះដើម្បីជំនុំជម្រះ ប៉ុន្តែពុំទទួលបានលទ្ធផល[87]។ ដោយសារការបកស្រាយម្យ៉ាងវិញទៀតថា រឿងក្តីនេះត្រូវបានដល់ទីបញ្ចប់ ហើយសំណុំរឿងពុំបាន និងពុំអាចដំណើរការបន្តទៀតនោះ អង្គជំនុំជម្រះសាលាដំបូងជាធម្មតាពុំចាំបាច់ធ្វើចំណាត់ការ និងជាចុងបញ្ចប់ បានចេញសេចក្តីប្រកាសព័ត៌មានជាសាធារណៈសម្រាប់គោលបំណងផ្តល់ការបំភ្លឺពីជំហររបស់ខ្លួន។ ដូចបានអះអាងដោយសហព្រះរាជអាជ្ញាអន្តរជាតិបញ្ហាចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល គឺថាតើ ភាពអសកម្មរបស់អង្គជំនុំជម្រះសាលាដំបូង រួមទាំងការខកខានក្នុងការអនុញ្ញាតការដាក់ឯកសារក្នុងប្រព័ន្ធអេឡិចត្រូនិច និងការជូនដំណឹង បន្ទាប់មកការបង្វិលឯកសារទាំងអស់ទៅភាគីវិញ បូកជាមួយនឹងការចេញសេចក្តីប្រកាសព័ត៌មាន គឺស្មើនឹងការចេញសេចក្តីសម្រេចមួយដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី ដែលធ្វើឱ្យបណ្តឹងសាទុក្ខនេះអាចទទួលយកបានតាមទម្រង់ ដែរ ឬយ៉ាងណា[88]។

49. សំណួរនេះ ពុំអាចត្រូវបានឆ្លើយដោយពុំបានដោះស្រាយជាមុនលើបញ្ហា ថាតើ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានទទួលដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ ដែរ ឬយ៉ាងណា ដែលជាការជំនុំ

---

[86] *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបំបែកនីតិវិធីលើកទីពីរ កថាខណ្ឌ ២១ និងទីមួយ កថាខណ្ឌ ២២ *យោងទៅលើ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារលេខ E138/1/7 កថាខណ្ឌ ១៥។

[87] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៦ ដល់ ៩ ១០ ដល់ ៣០។ *សូមមើលផងដែរ* ផ្នែកប្រវត្តិនីតិវិធី*ខាងលើ*។

[88] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤១ ដល់ ៤៥។

ជម្រះក្នុងសំណុំរឿង ០០៤/២ ប្រឆាំងនឹង អោ អាន។ ចំណាត់ការជាជំហានដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិក្នុងការដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង ព្រមទាំងស្នើសុំការិយាល័យរដ្ឋបាលជួយសម្រួលការបញ្ជូនសំណុំរឿងនេះ កើតចេញពីជំនឿរបស់ខ្លួនថា អង្គជំនុំជម្រះសាលាដំបូងមានយុត្តាធិការលើសំណុំរឿង ប៉ុន្តែខកខានក្នុងការអនុវត្តយុត្តាធិការនេះ។ ទោះជាយ៉ាងណាក្តី ការពិតគឺថាសំណុំរឿងដែលនៅតែមានចំណាត់ថ្នាក់សម្ងាត់ ពុំដែលត្រូវបានបញ្ជូនជាផ្លូវការមកអង្គជំនុំជម្រះសាលាដំបូងឡើយ។ សំណុំរឿងនេះនៅជាប់គាំងនៅក្នុងការបង្គាប់ផ្ទុយគ្នាពីសំណាក់ចៅក្រមអង្គបុរេជំនុំជម្រះដែលការិយាល័យរដ្ឋបាលពុំមានតួនាទីក្នុងការអនុវត្តបានឡើយ[89]។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះមានការជាប់ពាក់ព័ន្ធក្នុងការរារាំងសេចក្តីសម្រេចរបស់ខ្លួនមិនឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះអាចអនុវត្តបាន និងរឿងក្តីត្រូវ"ស្ថិតក្នុងភាពមិនច្បាស់លាស់"[90]។ ចៅក្រមអន្តរជាតិបានបញ្ចេញទស្សនៈរបស់ខ្លួនថាកាលៈទេសៈនៅក្នុងរឿងក្តីនេះបង្ហាញថា "ពុំអាចឱ្យអង្គជំនុំជម្រះមួយនៃ អ.វ.ត.ក. មានលទ្ធភាពចាត់វិធានការតាមផ្លូវតុលាការបាននៅពេលដែលមានការផ្ទុយគ្នាទៅលើភាពចាំបាច់ក្នុងការធ្វើដូច្នោះ"[91]។ ចៅក្រមជាតិតាមរយៈប្រធានអង្គបុរេជំនុំជម្រះបានទាមទារស្របគ្នាថា សំណុំរឿង ០០៤/២ ប្រឆាំងនឹង អោ អាន ត្រូវបញ្ចប់ ដោយស្របតាមសេចក្តីសម្រេចរបស់ខ្លួនគាំទ្រដីកាលើកលែងចោទប្រកាន់។

50. ផ្អែកតាមដំណើរធម្មតានៃព្រឹត្តិការណ៍ក្នុងក្របខ័ណ្ឌផ្លូវច្បាប់របស់ អ.វ.ត.ក. ការជូនដំណឹង និងការបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង ទើបអង្គជំនុំជម្រះសាលាដំបូងអាចទទួលយកសំណុំរឿង និងចាត់វិធានការណាមួយបាន[92]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា "ខ្លួនពុំដែលបានទទួលការជូនដំណឹងជាផ្លូវការនៃរឿងក្តី និងពុំដែលបានទទួលសំណុំរឿងនោះឡើយ"[93]។ ច្បាស់ណាស់ថា

[89] លិខិតផ្ទុយគ្នាពីរត្រូវបានផ្ញើទៅកាន់ការិយាល័យរដ្ឋបាល និងផ្សេងទៀតដោយប្រធានអង្គបុរេជំនុំជម្រះ និងដោយចៅក្រមអន្តរជាតិ បានធ្វើឱ្យការិយាល័យរដ្ឋបាលស្នើសុំការបំភ្លឺទាក់ទងទៅនឹងបញ្ហា ថាតើការបង្គាប់មួយណាត្រូវយកទៅអនុវត្ត ឬជាជម្រើសសុំការបង្គាប់ដែលអាចអនុវត្តបាន។ អង្គបុរេជំនុំជម្រះពុំបានផ្តល់ចម្លើយរហូតដល់បច្ចុប្បន្ន និងពុំមានការបង្គាប់ណាមួយត្រូវបានយល់ព្រមពីចៅក្រមទាំងអស់របស់អង្គបុរេជំនុំជម្រះ។

[90] អនុស្សរណៈអន្តរការិយាល័យរបស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០។

[91] សេចក្តីប្រកាសព័ត៌មានថ្ងៃទី ០៣ ខែ មេសា។

[92] មាត្រា ២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារចំពោះមុខ អ.វ.ត.ក.។

[93] សេចក្តីប្រកាសព័ត៌មានថ្ងៃទី ០៣ ខែ មេសា។

អង្គជំនុំជម្រះសាលាដំបូងពិតជាពុំដែលបានទទួលសំណុំរឿងតាមរយៈយន្តការផ្នែករដ្ឋបាល និងនីតិវិធីសមស្រប ដូចមានចែងក្នុងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក.។

51. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា នៅក្នុងផ្នែកសម្រេចសេចក្តីនៃសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ចៅក្រមបានប្រកាស*ជាឯកច្ឆន្ទ*ដូចខាងក្រោមថា៖

- "**បង្គាប់**ឱ្យមានការបញ្ចូលគ្នានៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរ
- **សម្រេច**ថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិត្រឹមត្រូវតាមទម្រង់
- **សម្រេច**ថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិត្រឹមត្រូវតាមទម្រង់
- **សម្រេច** ទាក់ទងទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តីរបស់ អោ អាន ថា ទឡ្ហីករណ៍ទី១ ដល់ ៩ ១១ ១២(i) ១៣ ១៥(i) ១៦(ii) ទាំងនោះអាចទទួលយកបាន
- **សម្រេច**ថា ទឡ្ហីករណ៍ដែលនៅសល់ក្នុងបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អោ អាន ពុំអាចទទួលយកបាន
- **ប្រកាស**ថា អង្គបុរេជំនុំជម្រះអាចប្រើប្រាស់សិទ្ធិអំណាចលើការពិនិត្យឡើងវិញនៃបញ្ហាកិច្ចស៊ើបសួរ
- **ប្រកាស**ថា ផ្អែកលើយុត្តាធិការនៃ អ.វ.ត.ក តុលាការសាមញ្ញកម្ពុជាមានយុត្តាធិការពេញលេញលើបញ្ហានៃយុត្តិធម៌រឿងក្តីព្រហ្មទណ្ឌ
- **ប្រកាស**ថា ការពន្យារក្នុងការចេញដីកាដំណោះស្រាយបន្ទាប់ពីបញ្ចប់កិច្ចស៊ើបសួរប្រឆាំងនឹង អោ អាន ពុំមានភាពចាំបាច់
- **ប្រកាស**ថា សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការវាយតម្លៃលើភាពជឿទុកចិត្ត និងតម្លៃភស្តុតាង
- **ប្រកាស**ថា ការចេញដីកាពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ ដោយរំលោភបំពានលើក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក.
- **ប្រកាស**ថា អង្គបុរេជំនុំជម្រះពុំអាចស្វែងរកសំឡេងគាំទ្រវិជ្ជមានឱ្យបានយ៉ាងតិចពីចៅក្រមបួនរូប សម្រាប់ចេញសេចក្តីសម្រេចដោយផ្អែកលើសំអាងហេតុរួមលើអង្គសេចក្តីបានឡើយ

  ផ្អែកលើវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចបច្ចុប្បន្នបិទផ្លូវតវ៉ា។

  ផ្អែកលើវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះត្រូវជូនដំណឹងទៅសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងភាគីដោយក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ"[94]។

52. ដោយបានប្រកាស*ជាឯកច្ឆន្ទ*នូវការយល់ឃើញខាងលើ អង្គបុរេជំនុំជម្រះបានបង្គាប់មិនឱ្យធ្វើការជូនដំណឹង ឬបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូង។ ផ្នែកសម្រេចសេចក្តី និងសេចក្តីប្រកាស

[94] *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ* ផ្នែកសម្រេចសេចក្តី (សេចក្តីបញ្ជាក់បន្ថែម)។

ដែលបានយល់ស្រប *ជាឯកច្ឆន្ទ* ត្រូវបានឯកភាពដោយចៅក្រមប្រាំរូបរបស់អង្គបុរេជំនុំជម្រះដែលបានភ្ជាប់នូវហត្ថលេខារបស់ខ្លួនផងនោះ។

53. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ទោះបីជាមានសេចក្តីប្រកាស*ឯកច្ឆន្ទ*ដែលថា ចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញជាដីកាដំណោះស្រាយពីរដាច់ដោយឡែក ហើយផ្ទុយគ្នា ចាត់ទុកជាមោឃភាពក៏ដោយ ក៏ចៅក្រមអង្គបុរេជំនុំជម្រះផ្តល់សេចក្តីពិចារណារបស់ខ្លួនលើសុពលភាពនៃដីកាដំណោះស្រាយផ្ទុយគ្នានេះដែរ។ ជាការជាក់ច្បាស់ណាស់ដែលថា ការធ្វើបែបនេះគឺជាការអនុវត្តន៍ដែលពុំចាំបាច់។ រឹតតែមិនជាប់ពាក់ព័ន្ធទៀតថា អង្គបុរេជំនុំជម្រះពុំបានទទួលមតិភាគច្រើនលើសលុប ដែលតម្រូវក្នុងការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ភាគីប្រឆាំងនឹងដីកាដែលផ្ទុយគ្នា ដោយសារផ្នែកសេចក្តីពិចារណាលើផ្នែកនេះទៅជារឿងលែងចាំបាច់[95]។

54. អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ផ្អែកលើការយល់ឃើញទាំងនេះ អង្គជំនុំជម្រះសាលាដំបូងពុំមានតួនាទីក្នុងការអនុញ្ញាត និង/ឬជូនដំណឹងអំពីការដាក់ឯកសារតាមប្រព័ន្ធអេឡិចត្រូនិច។ ដូច្នេះការបង្វិលការដាក់ឯកសារទាំងនោះទៅភាគីវិញ ជាលទ្ធផលជៀសពុំរួច។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា សារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីភាពអសកម្មរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានលើកឡើងនោះ ពុំទទួលបានជោគជ័យឡើយ។

55. អំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា ការចេញសេចក្តីប្រកាសព័ត៌មានថ្ងៃទី ០៣ ខែ មេសា បង្កើតបានជាសេចក្តីសម្រេចនោះ ក៏ពុំទទួលបានជោគជ័យដែរ[96]។ សារណាពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ ដោយបញ្ជាក់ថា អនុស្សរណៈរបស់អង្គបុរេជំនុំជម្រះបង្កើតបានជា"សេចក្តីសម្រេច" ពីព្រោះមាន"*ការបញ្ជាក់អំពី* កិច្ចរបស់តុលាការដែលមានអានុភាពផ្លូវច្បាប់ បើទោះបីជាខ្វះទម្រង់ជាក់លាក់ក៏ដោយ"[97] និងការយល់ឃើញថា "ការអនុវត្តន៍ដែលងាកចេញពីទម្រង់បែបបទ និងនិមិត្តរូបផ្លូវការរបស់តុលាការ ពុំបានចាត់ទុកកិច្ចទាំងអស់

---

[95] *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ* កថាខណ្ឌ ១៦៩។

[96] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤៥។

[97] *យោង*សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងវិសាលភាពសំណុំរឿង ០០២/០១ ("បណ្តឹងសាទុក្ខភ្លាមៗលើវិសាលភាពនៃសំណុំរឿង ០០២/០១") ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារលេខ E163/5/1/13 កថាខណ្ឌ ៣០។

នោះថា គ្មានសុពលភាព”[98]នោះ ពុំតម្រូវឱ្យមានការពិចារណាឡើយ។ ប៉ុន្តែទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះមានបំណងលើកឡើងថា អង្គជំនុំជម្រះធ្វើការវែកញែកភាពខុសគ្នារវាងសំណុំរឿង ០០២/០១ ត្រង់ចំណុចដែល អនុស្សរណៈមានបញ្ជាក់ហេតុផលដែលដោះស្រាយលើបញ្ហាពាក់ព័ន្ធទៅនឹងវិសាលភាពនៃការជំនុំជម្រះ ត្រូវបានចេញ និងសំណុំរឿង ០០៤/២ ត្រង់ចំណុចដែលសេចក្តីប្រកាសព័ត៌មាន ក្នុងគោលបំណងផ្តល់ការបំភ្លឺដល់ភាគី និងមហាជន អំពីស្ថានការណ៍ពាក់ព័ន្ធទៅនឹងដីកាដំណោះស្រាយពីរផ្ទុយគ្នាដែលមិនអាចឱ្យមានការបញ្ជូនសំណុំរឿងទៅមុខបាន។

56. បន្ថែមលើនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កាលៈទេសៈនៃរឿងក្តី ០០២/០១ និងរឿងក្តី ០០៤/២ ពុំអាចប្រៀបធៀបគ្នាបានឡើយ ជាពិសេសពាក់ព័ន្ធទៅនឹងការបញ្ជាក់យ៉ាងឥតព្រលាំរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា “ការចេញសេចក្តីសម្រេចផ្លូវការ” ពុំអាចធ្វើទៅបាន និងថាសេចក្តីប្រកាសព័ត៌មាននេះ“ពុំមានអានុភាពគតិយុត្តិ”ឡើយ[99]។ អាស្រ័យហេតុនេះ សេចក្តីប្រកាសព័ត៌មានថ្ងៃទី ០៣ ខែ មេសា ពុំអាចត្រូវបានបកស្រាយថា ជាសេចក្តីសម្រេចដែលអាចធ្វើបណ្តឹងសាទុក្ខបានដូច្នេះហើយការបកស្រាយបែបនេះមានឧត្តមភាពខ្ពង់ខ្ពស់។

***សេចក្តីសន្និដ្ឋាន***

57. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សម្រាប់សេចក្តីសម្រេចណាដែលមានអានុភាពផ្លូវច្បាប់ និងអាចអនុវត្តបាន ជាចាំបាច់ត្រូវតែជាសេចក្តីសម្រេចមួយដែលធ្វើឡើងដោយអង្គជំនុំជម្រះមួយដែលមានយុត្តាធិការក្នុងការប្រកាស និងត្រូវតែក្នុង*ចំណោមទោះ*ដោះស្រាយបញ្ហាផ្លូវច្បាប់លើកឡើងដោយភាគី។ ដោយសារអង្គជំនុំជម្រះសាលាដំបូងពុំបានទទួលសំណុំរឿង ០០៤/២ ទើបអង្គជំនុំជម្រះពុំមានយុត្តាធិការចេញដីកាត្រឹមត្រូវតាមច្បាប់ណាមួយបាន។ ដោយពុំដែលបានទទួលសំណុំរឿង ដូច្នេះពុំមានភាគីណាមួយនៅចំពោះមុខខ្លួន និងពុំមានផ្នែកសម្រេចសេចក្តីណាមួយត្រូវបានចេញដោយអង្គជំនុំជម្រះសាលាដំបូងឡើយ។ សកម្មភាព និងភាពអសកម្មដែលបានចោទប្រកាន់ និងសេចក្តីប្រកាសព័ត៌មានថ្ងៃទី ០៣ ខែ មេសា បើទោះបីជាដាច់ដោយឡែក ឬរួមគ្នាក៏ដោយ ក៏ពុំបង្កើតបានជាសេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខបានឡើយ។ ជាការបញ្ជាក់សាជាថ្មី អង្គជំនុំជម្រះសាលាដំបូងពុំអាចបញ្ចប់អានុភាពកិច្ចដំណើរការនីតិវិធីបាន ដោយសារអង្គជំនុំជម្រះពុំបានទទួលសំណុំរឿងជាផ្លូវការ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះ

---

[98] បណ្តឹងសាទុក្ខភ្លាមៗលើវិសាលភាពនៃសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០។

[99] សេចក្តីប្រកាសព័ត៌មានថ្ងៃទី ០៣ ខែ មេសា។

ពិចារណាឃើញថា បណ្តឹងសាទុក្ខភ្លាមៗនេះពុំស្របតាមបទប្បញ្ញត្តិនៃវិធាន ១០៤(៤)(ក)នៃវិធានផ្ទៃក្នុង ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ផ្អែកលើមូលដ្ឋាននេះ បណ្តឹងសាទុក្ខភ្លាមៗនេះពុំត្រឹមត្រូវតាមទម្រង់។

## *ភាពអាចទទួលយកបានជាជម្រើសមួយផ្សេង*

### *ការពិភាក្សា*

58. ជាជម្រើស សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យប្រើប្រាស់យុត្តាធិការនៃឆន្ទានុសិទ្ធិក្នុងការយល់ឃើញថា បណ្តឹងសាទុក្ខនេះត្រឹមត្រូវតាមទម្រង់ដោយផ្អែកលើមូលដ្ឋានថា "មានភាពចាំបាច់តម្រូវឱ្យមានការធានានូវរដ្ឋបាលតុលាការល្អ និងយុត្តិធម៌"[100]។ អង្គជំនុំជម្រះនឹងត្រូវបន្តធ្វើការកំណត់ដោយផ្អែកលើមូលដ្ឋាននេះ។

59. នេះគឺជាបញ្ហាដ៏លំបាកមួយ។ ប្រវត្តិនីតិវិធីនៃបណ្តឹងសាទុក្ខភ្លាមៗបានបង្ហាញកាលៈទេសៈខុសពីធម្មតាដែលនាំទៅរកភាពទាល់ច្រកជាអត្ថិភាពក្នុងសំណុំរឿង ០០៤/២។ សូម្បីត្រឹមតែវិភាគត្រួសៗលើសាវតារនីតិវិធីនៃសំណុំរឿង ០០៤/២ បង្ហាញឱ្យឃើញពីការខ្វែងយោបល់ជាច្រើនដែលបានកើតឡើងរវាងសហព្រះរាជអាជ្ញា ចាប់តាំងពីឆ្នាំ ២០០៨ ហើយបានបន្តរហូតអស់ជាងមួយទសវត្សរ៍នៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត បានឈានទៅរកដីកាដំណោះស្រាយដែលគេចពុំរួចពីការផ្ទុយគ្នាស្ទើរតែទាំងស្រុងដែលចុងក្រោយបានមកដល់មុខអង្គបុរេជំនុំជម្រះ[101]។ បើទោះបីជាមានការលំបាក និងបើទោះជាយ៉ាងណាក្តី ក៏អង្គជំនុំជម្រះតុលាការកំពូលមិនត្រូវបង្រួមការលំបាកយ៉ាងខ្លាំងដែលអង្គបុរេជំនុំជម្រះបានប្រឈមទុកមួយអន្លើនោះឡើយ គឺត្រូវដោះស្រាយបញ្ហានេះ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកអំពីច្បាប់រ៉ូម៉ាំងម៉ាកស៊ីម (Roman Law maxim) *ubi jus, ibi remedium* មានន័យថា ទីណាមានសិទ្ធិ ទីនោះមានសំណង ទីណាច្បាប់បង្កើតសិទ្ធិ ទីនោះគប្បីមានសំណងតបទៅនឹងការរំលោភសិទ្ធិ។

60. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កាលៈទេសៈពិសេសនៃសំណុំរឿង ០០៤/២ តម្រូវថា សហព្រះរាជអាជ្ញា អោ អាន ដើមបណ្តឹងរដ្ឋប្បវេណី និងសាធារណជន មានសិទ្ធិទទួលបានការ

---

[100] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤៦ ដល់ ៤៩។

[101] *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ* កថាខណ្ឌ ១៦៩។ តាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង មតិរបស់ចៅក្រមនីមួយៗនៃអង្គបុរេជំនុំជម្រះ ត្រូវបានភ្ជាប់នៅក្នុងនោះដែរ និងផ្នែកសម្រេចសេចក្តី។

រំពឹងទុក និងទទួលបានភាពប្រាកដប្រជា និងច្បាស់លាស់ក្នុងរឿងក្តីនេះ។ ការទុកឱ្យស្ថិតក្នុងភាពមិនច្បាស់លាស់តាមផ្លូវតុលាការ បានបំពានជាមូលដ្ឋាននូវក្តីរំពឹងត្រឹមត្រូវតាមច្បាប់ទាំងនោះ។ ដូច្នេះអង្គជំនុំជម្រះនេះ គឺជាដំណាក់កាលចុងក្រោយក្នុងការផ្តល់នូវភាពជាក់លាក់នេះ។

61. គួររំឭកផងដែរថា អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា "ក្នុងរឿងក្តីជាក់លាក់នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង បានចែងថា ខ្លួនមានសិទ្ធិអំណាចក្នុងការចេញដីកាដំណោះស្រាយថ្មី ឬកែប្រែដីកាដំណោះស្រាយនោះដែលនឹងធ្វើជាមូលដ្ឋានសម្រាប់ការជំនុំជម្រះ"[102] និងបានសង្កត់ធ្ងន់ថា ខ្លួន"បានសម្រេចរួចមកហើយថា អង្គបុរេជំនុំជម្រះបំពេញតួនាទីស៊ើបអង្កេតរបស់កម្ពុជានៅ អ.វ.ត.ក. ដែលនៅពេលបានទទួលដីកាលើកលែងចោទប្រកាន់ដោយសារផលវិបាកនៃបណ្តឹងឧទ្ធរណ៍ត្រូវស៊ើបអង្កេតរឿងក្តីដោយខ្លួនឯង"[103]។ ការយល់ឃើញច្បាស់លាស់នេះនឹងនាំអ្នកវិភាគសមហេតុផលអាចសន្និដ្ឋានបានថា អង្គបុរេជំនុំជម្រះបានដឹងអំពីសិទ្ធិអំណាចរបស់ខ្លួនក្នុងការធ្វើលើសពីការប្រកាសភាពខុសច្បាប់នៃស្ថានការណ៍ដែលពាក់ព័ន្ធទៅនឹងការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា និងចេញដីកាដំណោះស្រាយសុពលភាពរបស់ខ្លួនថ្មីមួយបាន។ ទោះជាយ៉ាងណាក្តី អង្គបុរេជំនុំជម្រះពុំបានជ្រើសយកវិធីសាស្ត្របែបនេះទេ។ អង្គបុរេជំនុំជម្រះ បន្ទាប់ពីបានប្រកាស*ជាឯកច្ឆន្ទ*ថា "ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ ដោយរំលោភក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក." គប្បីចាប់យកមួយជំហានបន្ថែមទៀត និងផ្តល់នូវការសម្រេចស្ថាពរជាក់ស្តែង។

62. ក្នុងការពិចារណាអំពីព្រឹត្តិការណ៍ខាងលើដ៏លំបាក មិនដែលធ្លាប់មាន និងជាបញ្ហារសើបផងនោះ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ក្នុងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក. ប្រធានបទដដែលៗនៃ*ការឯកច្ឆន្ទ* គឺ

---

[102] *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ* ឯកសារលេខ D359/24 និង 360/33 ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៩ កថាខណ្ឌ ៣០ *ដកស្រង់* សេចក្តីពិចារណាសំណុំរឿង ០០៤/១ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ឯកសារលេខ D308/3/1/20 កថាខណ្ឌ ២២ *យោងទៅលើ* សំណុំរឿង ០០១ អង្គបុរេជំនុំជម្រះ ០២ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចោទប្រកាន់ កាំង ហ្កេច អ៊ាវ *ហៅ* "ឌុច" ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ ឯកសារលេខ D99/3/42 ("សេចក្តីសម្រេចលើសំណុំរឿង ០០១ ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ") កថាខណ្ឌ ៤០។

[103] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៣០ យោងទៅលើសេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/១ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤១ ដល់ ៤២។

សំខាន់បំផុតក្នុងដំណើរការធ្វើសេចក្តីសម្រេច[104]។ ទោះជាយ៉ាងណាក្តី មានការទទួលស្គាល់ថា នៅពេលដែលការឯកច្ឆន្ទ ពុំទទួលបាននៅក្នុងដំណាក់កាលណាមួយនៃកិច្ចស៊ើបសួរ និងការចោទប្រកាន់ក្នុងដំណើរការមុនការជំនុំជម្រះ នឹង *មានជំហរមិនពេញលេញ*ដែលជួយដល់ការបន្តកិច្ចស៊ើបសួរ ឬការចោទប្រកាន់ បញ្ហាថាតើ ជារបស់សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា។ ក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក. ពុំបានដោះស្រាយលើលទ្ធភាពនៃដីកាដំណោះស្រាយពីរដែលមានទិសដៅផ្ទុយគ្នាទាំងស្រុង និងឈានមកដល់ដំណាក់កាលនេះកើតចេញពីការវិភាគចំនួនពីរដោយយកចិត្តទុកដាក់លើអំពើ ដែលត្រូវបានសន្មតថា ជារបស់ជនសង្ស័យតែមួយដូចគ្នា ទីកន្លែងឧក្រិដ្ឋកម្មតែមួយ និងពេលវេលាតែមួយដូចគ្នា។ ការខ្វែងយោបល់ដែលគ្មានលទ្ធភាពអាចសម្របសម្រួលបានរបស់សហចៅក្រមស៊ើបអង្កេតលើបញ្ហា ថាតើ អោ អាន គប្បីត្រូវបានស៊ើបអង្កេត *ដែរ ឬយ៉ាងណា* បាននាំសហចៅក្រមស៊ើបអង្កេតដល់ការចុះបញ្ជីជាផ្លូវការនូវការខ្វែងយោបល់មួយចំនួនជាមូលដ្ឋាន និងជៀសពុំរួចដល់ការចេញដីកាដំណោះស្រាយផ្ទុយគ្នា ម្ខាងលើកលែងការចោទប្រកាន់ និងម្ខាងទៀតធ្វើការចោទប្រកាន់ អោ អាន។ ភាពខ្វែងយោបល់ទាំងនេះដែលហាក់បីដូចជាប្រកាន់នូវគំនិតរឹងត្អឹង និងខ្លាំងក្លារៀងៗខ្លួន បាននាំសំណុំរឿង ០០៤/២ បច្ចុប្បន្នទៅរកភាពទាល់ច្រក។

63. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ការពិនិត្យរួមគ្នាលើវិធាន ២ នៃវិធានផ្ទៃក្នុង[105] ព្រមទាំងមាត្រា ២០ *ថ្មី* ២៣ *ថ្មី* និង ៣៣ *ថ្មី* នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក. និងបុព្វកថានៃកិច្ចព្រមព្រៀង បានអនុញ្ញាតអង្គជំនុំជម្រះស្វែងរកការបំភ្លឺពីបទដ្ឋានអន្តរជាតិ ត្រង់ចំណុចដែលក្របខ័ណ្ឌច្បាប់នៃ អ.វ.ត.ក. មានការខ្វះចន្លោះក្នុងការដោះស្រាយលើបញ្ហាជាក់លាក់ ឬប្រសិនបើមានភាពមិនប្រាកដប្រជាទាក់ទងនឹងការបកស្រាយ ឬការអនុវត្តន៍ជាដើម[106]។

---

[104] មាត្រា ៤ នៃកិច្ចព្រមព្រៀង។ មាត្រា ១៤ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ វិធាន ៩៨(៤) វិធាន ១០១(២) វិធាន ១១១(៦) វិធាន ១១២(៣) វិធាន ១២ ស្ទួនបី (៣) វិធាន ៣៩(៥) វិធាន ៧១(៣) វិធាន ៧២(៣) នៃវិធានផ្ទៃក្នុង។

[105] វិធាន ២ នៃវិធានផ្ទៃក្នុងចែងអំពីការបំភ្លឺក្នុងកាលៈទេសៈ"ដែលក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី នៅពេលមានបញ្ហាកើតឡើង ដែលពុំអាចដោះស្រាយបាននៅក្នុងវិធានផ្ទៃក្នុងទាំងនេះទេ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវសម្រេចដោយផ្អែកតាមវិធាន ១២(១) នៃកិច្ចព្រមព្រៀង និងមាត្រា ២០ ថ្មី ២៣ ថ្មី ៣៣ ថ្មី ឬ ៣៧ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ដែលជាធរមាន ដោយត្រូវយកចិត្តទុកដាក់យ៉ាងពិសេសទៅលើគោលការណ៍សារវន្តដែលបានកំណត់ក្នុងវិធាន ២១ និងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ [..]"

[106] កិច្ចព្រមព្រៀង បុព្វកថា។

64. ដូចបានលើកឡើងខាងលើ ផ្អែកតាមនីតិរដ្ឋទូទៅថា ជាការមិនសមស្របដែលបញ្ហាផ្លូវច្បាប់ត្រូវបន្សល់ទុកមិនដោះស្រាយ។ តុលាការចុងក្រោយគឺអង្គជំនុំជម្រះតុលាការកំពូល ដែលមានកាតព្វកិច្ចស្រាយបំភ្លឺ និងបញ្ចប់ស្ថានការណ៍បែបនេះ។ ការជាប់គាំងផ្នែកច្បាប់ សឱ្យឃើញពីភាពបរាជ័យនៃប្រព័ន្ធតុលាការក្នុងការសងសំណង។ ដោយហេតុថា សហព្រះរាជអាជ្ញាអន្តរជាតិកំពុងធ្វើចំណាត់ការដោយពុំមានការគាំទ្រ ឬជំទាស់ពីសហព្រះរាជអាជ្ញាជាតិនៅក្នុងបណ្តឹងសាទុក្ខភ្លាមៗ កាន់តែពង្រីកភាពទាល់ច្រកផ្នែកច្បាប់ដែលកើតមានគ្មានទីបញ្ចប់នៅគ្រប់ជំហាននៃដំណើរការស៊ើបអង្កេតនៃសំណុំរឿង ០០៤/២ ប្រឆាំងនឹង អោ អាន។ សាជាថ្មីម្តងទៀត នេះបញ្ជាក់ថា ក្របខ័ណ្ឌច្បាប់បច្ចុប្បន្នរបស់ អ.វ.ត.ក. ពុំបានដោះស្រាយបញ្ហានេះតាមការស្តែងចេញឱ្យឃើញច្បាស់លាស់នោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា នេះគឺជាកាតព្វកិច្ចក្នុងនាមជាអង្គជំនុំជម្រះឧទ្ធរណ៍ និងតុលាការជាន់ខ្ពស់ចុងក្រោយ[107] ក្នុងការផ្តល់សំណងផ្លូវច្បាប់ និងធ្វើការកំណត់ចុងក្រោយក្នុងរឿងក្តី ដែលលក្ខន្តិកៈ ឬច្បាប់ ពុំមានចែង ឬមិនច្បាស់លាស់។ នេះគឺជាតួនាទីរបស់តុលាការចុងក្រោយក្នុងការផ្តល់ភាពប្រាកដប្រជាផ្នែកច្បាប់ដល់ភាគី។ យោងតាមសំអាងហេតុ អង្គជំនុំជម្រះតុលាការកំពូលនឹងពិចារណាលើបណ្តឹងសាទុក្ខភ្លាមៗនេះ។

## *សេចក្តីសន្និដ្ឋាន*

65. ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថាជាការចាំបាច់ក្នុងការផ្តល់ភាពប្រាកដប្រជា និងការបំភ្លឺចំពោះបញ្ហាផ្លូវច្បាប់គន្លឹះដែលបានបង្ហាញនៅក្នុងបណ្តឹងសាទុក្ខភ្លាមៗនេះថា កម្រងឯកសារច្បាប់ អ.វ.ត.ក. ពុំបានដោះស្រាយជាក់លាក់ឡើយ។ នៅក្នុងកាលៈទេសៈជាក់លាក់នៃសំណុំរឿង ០០៤/២ ប្រឆាំងនឹង អោ អាន អង្គជំនុំជម្រះពិចារណាឃើញថា ដំណោះស្រាយ គឺជាភាពចាំបាច់លើសលុប ដូច្នេះ អង្គជំនុំជម្រះនឹងត្រូវប្រើប្រាស់ឆន្ទានុសិទ្ធិដើម្បីអត្ថប្រយោជន៍យុត្តិធម៌ និងភាពត្រឹមត្រូវ និងទទួលធ្វើការពិចារណាបណ្តឹងសាទុក្ខភ្លាមៗនេះយ៉ាងពិសេសដើម្បីធានាថា សច្ចភាពផ្លូវច្បាប់ និងការបញ្ចប់ ត្រូវទទួលបានក្នុងការកំណត់នៃរឿងក្តីនេះ និងបញ្ជាក់នូវសុចរិតភាពនៃស្ថាប័ន អ.វ.ត.ក.។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវដោះស្រាយទទ្បីករណ៍ពាក់ព័ន្ធនៃបណ្តឹងសាទុក្ខនេះ។

[107] មាត្រា ៩ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

## ឆ. អនុសេចក្តី

66. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយខកខានក្នុងការបន្តការជំនុំជម្រះ អោ អាន ចាប់តាំងពេលចេញសេចក្តីពិចារណារបស់ អង្គបុរេជំនុំជម្រះ កាលពីថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៩ ដូច្នេះ បានបញ្ចប់អានុភាពនៃសំណុំរឿង ០០៤/២។ សហព្រះរាជអាជ្ញាបានអះអាងថា ដោយសារអង្គបុរេជំនុំជម្រះមិនអាចរកមតិភាគច្រើនដែលតម្រូវបាន ទើបបង្កឱ្យមាននូវ*គោលជំហរមិនពេញលេញ*កើតឡើង[108]។

67. អំណះអំណាងដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ គឺថា ករណីពុំមានកិច្ចព្រមព្រៀង និងមតិភាគច្រើនលើសលុបគាំទ្រដីកាលើកលែងចោទប្រកាន់*គោលជំហរមិនពេញលេញ*ត្រូវចាត់ទុកជាបានការ។ អំណះអំណាងនេះគេចវេស ឬមិនអើពើផលវិបាកនៃការយល់ឃើញ*ឯកច្ឆន្ទ*របស់អង្គបុរេជំនុំជម្រះ ដែលថា ដីកាដំណោះស្រាយគឺជាលទ្ធផលនៃ*ចំណាត់ការខុសច្បាប់ និងពុំត្រឹមត្រូវតាមច្បាប់*។ កិច្ចដែលគ្មានសុពលភាព មិនអាចបង្កើតផលវិបាក ឬលទ្ធផលត្រឹមត្រូវតាមច្បាប់។ អាស្រ័យហេតុនេះ ជាការសមហេតុផលដែលថា ចំណាត់ការប្រភពដើមដែលជាដីកាដំណោះស្រាយនីមួយៗនោះ ពុំមានអានុភាពផ្លូវច្បាប់។

68. ការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា *គោលជំហរមិនពេញលេញ* ត្រូវបានគាំទ្រដោយវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ដែលតាមគោលការណ៍*ច្បាប់ស្តីពីការគ្រប់គ្រងកម្មវត្ថុរឿងក្តីជាក់លាក់*ពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានអាទិភាពលើវិធាន ៧៧(១៣)(ក)នៃវិធានផ្ទៃក្នុងដែលជាវិធានទូទៅពាក់ព័ន្ធទៅនឹងដីកាទូទៅ"ជាជាងដីកាចោទប្រកាន់" មិនអាចកំណត់ដាច់ដោយឡែកម្នាក់ឯងបានទេ[109]។ នេះនៅតែជាបញ្ហាស្នូលដែលគួរតែបានដោះស្រាយដោយអង្គបុរេជំនុំជម្រះ។ ប្រហាក់ប្រហែលគ្នានេះដែរ បញ្ហាថាតើ វិធាន ១(២) នៃវិធានផ្ទៃក្នុងបានអនុញ្ញាតថៅក្រមស៊ើបអង្កេតបំពេញកិច្ចជាលក្ខណៈបុគ្គលនីមួយៗ នៅតែពុំទាន់បានដោះស្រាយដោយអង្គបុរេជំនុំជម្រះ[110]។ ដោយហេតុថា ជាការជាក់ច្បាស់ គោលបំណងនៃកិច្ចព្រមព្រៀង និងច្បាប់របស់ អ.វ.ត.ក. គឺដើម្បី"នាំយកមេដឹកនាំជាន់ខ្ពស់នៃ

---

[108] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៥០។

[109] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៥២។

[110] បណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៥៤ ដល់ ៥៥។

កម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតមកកាត់ទោសពីបទឧក្រិដ្ឋ”[111] ទើបត្រូវធ្វើឡើងផ្អែកតាមវិសាលភាពនៃច្បាប់។ នៅពេលអង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា គោលដៅនៃយន្តការដោះស្រាយការខ្វែងយោបល់គ្នា គឺត្រូវ“ទប់ស្កាត់ភាពទាល់ច្រកមិនអោយរារាំងកិច្ចដំណើរការនីតិវិធីបន្តដំណើរទៅរកការជំនុំជម្រះ[112] បញ្ហានៅក្នុងសំណុំរឿង ០០៤/២ គឺថាតើ រឿងក្ដីនេះឈានទៅជំនុំជម្រះក្នុងករណីពុំមានដីកាដំណោះស្រាយសុពលភាព(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។

69. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាដំណោះស្រាយទាំងពីរ បានបង្ហាញនូវវិសាលភាព និងទំហំនៃអំពើឃោរឃៅនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងពេលនោះ។ បើទោះបីជាមានការឯកភាពពាក់ព័ន្ធទៅនឹងចំនួនជនរងគ្រោះជាច្រើននៅក្នុងភូមិភាគកណ្ដាលក៏ដោយ ក៏ពុំមានការឯកភាពបន្ទាប់ពីរយៈពេលដប់បីឆ្នាំនៃកិច្ចស៊ើបសួរដែល អោ អាន ស្ថិតក្នុងយុត្តាធិការរបស់តុលាការ។ អង្គជំនុំជម្រះពិចារណាឃើញថា ក្នុងករណីពុំមានដីកាដែលអាចអនុវត្តបាន និងជាក់លាក់ ប្រឆាំងនឹង អោ អាន សំណុំរឿង ០០៤/២ ប្រឆាំងនឹងរូបគាត់ គប្បីត្រូវបញ្ចប់នៅចំពោះមុខ អ.វ.ត.ក.។

## *សេចក្តីសន្និដ្ឋាន*

70. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំដែលបានទទួលសំណុំរឿង ០០៤/២ និងដូច្នេះ ពុំមានកំហុសក្នុងការមិនបន្តការជំនុំជម្រះប្រឆាំងនឹង អោ អាន ដោយផ្អែកលើវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ដែលគាំទ្រគោលជំហរមិនពេញលេញ។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងពុំមានសិទ្ធិអំណាចធ្វើចំណាត់ការ ឬសម្រេចបញ្ហាណាមួយដែលបញ្ជូនមកចំពោះមុខខ្លួន។ រាល់ទឡ្ហីករណ៍ដទៃទៀតបានលើកឡើងក្នុងបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ជាលទ្ធផល ត្រូវបដិសេធចោល។

---

[111] បណ្ដឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៥៦ *យោងទៅលើ* មាត្រា ១ នៃកិច្ចព្រមព្រៀង អ.វ.ត.ក. និងមាត្រា ១ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[112] បណ្ដឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៥៦ *ដកស្រង់* កថាខណ្ឌ ៣២៣ មតិរបស់ចៅក្រមនីមួយៗរបស់អង្គបុរេជំនុំជម្រះ។

## ៥. សេចក្ដីសន្និដ្ឋាន

71. ផ្អែកលើការសង្កេតរបស់អង្គជំនុំជម្រះលើតម្រូវការចាំបាច់នៃសច្ចភាព និងការបញ្ចប់លើបញ្ហាសំខាន់ ដូចបានបង្ហាញក្នុងបណ្ដឹងសាទុក្ខភ្លាមៗទាក់ទងទៅនឹង សំណុំរឿង ០០៤/២ ប្រឆាំងនឹង អោ អាន អង្គជំនុំជម្រះបញ្ជាក់ដូចខាងក្រោម៖

i. អង្គជំនុំជម្រះសាលាដំបូងទទួលសំណុំរឿងត្រឹមត្រូវតាមច្បាប់ក្នុងករណីដែលអង្គបុរេជំនុំជម្រះបញ្ជូនសំណុំរឿងពាក់ព័ន្ធដោយផ្អែកតាមក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក.

ii. យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងមានអានុភាព លុះត្រាតែខ្លួនបានទទួលដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចអនុវត្តបានចេញដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ

iii. ភាគីក្នុងរឿងក្ដីនេះ មានសិទ្ធិទទួលបានការសម្រេចចុងក្រោយនៃរឿងក្ដីរបស់ខ្លួន

iv. សេចក្ដីប្រកាសព័ត៌មានដោយចៅក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០៤/២ ពុំបង្កើតបានជាសេចក្ដីសម្រេចដែលអាចប្ដឹងសាទុក្ខបាន ឬអាចអនុវត្តបាននោះទេ

v. ដោយផ្អែកលើការយល់ឃើញរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ដែលថា ការបំពេញកិច្ចរបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ មានន័យថា ពុំមានដីកាដំណោះស្រាយណាមួយមានសុពលភាពឡើយ

vi. ក្នុងករណីដែលពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលជាក់លាក់ និងអាចអនុវត្តបាន ដូចនេះ រឿងក្ដីប្រឆាំងនឹង អោ អាន ត្រូវបញ្ចប់នៅចំពោះមុខ អ.វ.ត.ក.។

## ឈ. ផ្នែកសម្រេចសេចក្ដី

យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖

**បណ្ដឹងសាទុក្ខភ្លាមៗ**អាចទទួលយកបានសម្រាប់ការបំភ្លឺអំពីបញ្ហាមួយចំនួន ដូចមានក្នុងផ្នែក **ជ** ខាងលើ

**បដិសេធ** បណ្ដឹងសាទុក្ខភ្លាមៗ។

**រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២០**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**